HEINRICH BÖLL STIFTUNG
ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia

របាយការណ៍

# ការការពារទិន្នន័យក្នុងបរិបទជនជាតិដើមភាគតិចនៅកម្ពុជា



របាយការណ៍រៀបចំដោយ៖
អង្គការទិន្នន័យអំពីការអភិវឌ្ឍ-អូឌីស៊ី
កក្កដា ២០២២



# មាតិកា

**១. ការកើនឡើងនូវបញ្ហាទិន្នន័យ និងករណីជនជាតិដើមភាគតិច**

ក. ទិដ្ឋភាពទូទៅនៃគោលគំនិតអំពីទិន្នន័យទាក់ទងនឹងឯកជនភាព
ខ. ករណីជាក់លាក់នៃទិន្នន័យជនជាតិដើមភាគតិច

**២. ការគំរាមកំហែងជាច្រើនពីការប្រមូលទិន្នន័យ និងការប៉ះពាល់ចំពោះជនជាតិដើមភាគតិច**

ក. សកម្មភាពមនុស្សធម៌របស់អង្គការមិនមែនរដ្ឋាភិបាលទាំងការជួយ និងបង្គ្រោះថ្នាក់ដល់ស្ថានភាពរបស់ជនជាតិដើមភាគតិច
ខ. ការចុះប្រមូលទិន្នន័យដោយរដ្ឋបាលសុរិយោដីក្នុងវិសាលភាពនៃការចុះបញ្ជីដីធ្លី

**៣. ខ្លឹមសារពាក់ព័ន្ធនៃបទប្បញ្ញត្តិថ្មីៗរបស់កម្ពុជាស្តីពីការការពារទិន្នន័យ**

ក. កង្វះប្រសិទ្ធភាពនៃច្បាប់បច្ចុប្បន្នក្នុងការការពារទិន្នន័យរបស់កម្ពុជារួមទាំងជនជាតិដើមភាគតិច
ខ. ដំណើរការនៃការងារច្បាប់ការពារទិន្នន័យ និងឥទ្ធិពលអន្តរជាតិមកលើនីតិរដ្ឋរបស់កម្ពុជាដែលកំពុងតែមានវឌ្ឍនភាព

**៤. សេចក្តីសន្និដ្ឋាន**



# សេចក្តីថ្លែងអំណរគុណ

Arthur Champeroux (កម្មសិក្សាការីស្រាវជ្រាវផ្នែកច្បាប់នៅអង្គការទិន្នន័យអំពីការអភិវឌ្ឍ-អូឌីស៊ី) បានចងក្រងអត្ថបទនេះឡើងតាមការណែនាំរបស់លោក ធី ទ្រី (នាយកប្រតិបត្ត/និពន្ធនាយកនៃអង្គការអូឌីស៊ី) និងដោយមានការចង្អុលបង្ហាញពីលោកស្រី Julià Puig (អ្នកស្រាវជ្រាវ និងមន្ត្រីយុទ្ធសាស្ត្រអង្គការអូឌីស៊ី)។ អ្នកនិពន្ធបានបញ្ចប់ការសិក្សាផ្នែកច្បាប់ពាណិជ្ជកម្មអន្តរជាតិ និងច្បាប់ឌីជីថល និងសន្តិសុខតាមប្រព័ន្ធអីនធឺណិតនៅសាលា Paris Assas II និងសាកលវិទ្យាល័យ Université de Grenoble Alpes ក្នុងឆ្នាំ២០២១។ អត្ថបទនេះអាចសម្រេចទៅបានដោយមានការចូលរួមផ្តល់យោបល់ណែនាំដ៏ថ្លៃថ្លាពីសំណាក់ក្រុមការងារអង្គការអូឌីស៊ី និងការជួយគាំទ្រពីក្រុមសាស្ត្រាចារ្យសាលា Paris Assas ។

កែសម្រួលដោយលោក David Hindley
រួមវិភាគទានដោយគេហទំព័រ https://cipocambodia.org/

ការប្រកាសបដិសេធ ៖ ទស្សនៈដែលបានបង្ហាញនៅក្នុងសៀវភៅនេះ គឺជាទស្សនៈសុទ្ធសាធរបស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់អង្គការអូឌីស៊ីទេ។ ទោះបីជាខ្លឹមសារនៃសៀវភៅនេះអាចដកស្រង់ និងផលិតឡើងវិញបាន ប៉ុន្តែត្រូវមានការទទួលស្គាល់ និងការអនុញ្ញាតពីអ្នកនិពន្ធ និងគ្រឹះស្ថានបោះពុម្ពផ្សាយរបាយការណ៍នេះ (https://creativecommons.org/licenses/by-nc-sa/4.0/) ។

ភាសា៖ អត្ថបទបោះពុម្ពផ្សាយនេះមានជាភាសាខ្មែរ អង់គ្លេស និងបារាំង។

សង្ខិត្តន័យ៖

ថ្មីៗនេះ សិទ្ធិរបស់ជនជាតិដើមភាគតិចនៅកម្ពុជាត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងៗ ជាពិសេសនៅក្នុងវិសាលភាពនៃការកាន់កាប់កម្មសិទ្ធិដីធ្លី។ ប៉ុន្តែការទទួលស្គាល់សិទ្ធិទាំងនេះ មិនបាននាំទៅរកដំណើរការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីដែលមានសុវត្ថិភាពរឹងមាំទេ។ ការអនុវត្តនីតិវិធីច្បាប់អាចប៉ះពាល់ដល់សិទ្ធិបុគ្គលរបស់ជនជាតិដើមភាគតិចក្នុងការទទួលបានឯកជនភាព ដោយសារទិន្នន័យរបស់ពួកគេដែលប្រមូលបាន ក្នុងអំឡុងពេលនៃការសាកសួរព័ត៌មានផ្នែករដ្ឋបាលត្រូវបានគេទុកចោលដោយគ្មានការការពារ។ បញ្ហានៃការការពារទិន្នន័យនៅក្នុងប្រទេសកម្ពុជា គឺជាការគំរាមកំហែងមួយទៀតចំពោះសិទ្ធិរបស់ជនជាតិដើមភាគតិច ដោយសារបញ្ហានេះនឹងរារាំងដល់អធិបតេយ្យភាពនៃទិន្នន័យជនជាតិដើមភាគតិច។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបង្កើតឧបករណ៍ និងគោលនយោបាយច្បាប់មួយចំនួន ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការការពារទិន្នន័យបែបទំនើប។ ដោយឡែក ទោះបីជាប្រព័ន្ធច្បាប់កម្ពុជាភាគច្រើនបាននិងកំពុងវិវដ្តទៅជារចនាសម្ព័ន្ធមួយកាន់តែមានប្រសិទ្ធភាព ដែលមានសមត្ថភាពក្នុងការការពារទិន្នន័យផ្ទាល់ខ្លួនក៏ដោយ ក៏ក្របខណ្ឌច្បាប់នៅតែកំពុងអភិវឌ្ឍ និងមិនទាន់អាចប្រឈមមុខនឹងបញ្ហាទាំងនេះនៅឡើយទេ។ មានក្តីសង្ឃឹមមួយចំនួនតាមរយៈគំនិតផ្តួចផ្តើមថ្នាក់តំបន់ និងអន្តរជាតិ ដូចជាសមិទ្ធផលការងារចុងក្រោយបង្អស់របស់អាស៊ាន ព្រមទាំងជំនោរនៃរលកបទប្បញ្ញត្តិការពារទិន្នន័យទូទៅរបស់សហភាពអឺរ៉ុប ដែលមានឥទ្ធិពលលើការអនុវត្តនៅក្នុងប្រទេសកម្ពុជា។

ពាក្យគន្លឹះ៖ ការការពារទិន្នន័យ គោលនយោបាយស្តីពីការការពារទិន្នន័យ ជនជាតិដើមភាគតិច អធិបតេយ្យភាពនៃទិន្នន័យជនជាតិដើមភាគតិច គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការចុះបញ្ជីដីធ្លី ច្បាប់ស្តីពីដីសម្បទាន ការប្រមូលទិន្នន័យ ឯកជនភាព សិទ្ធិផ្ទាល់ខ្លួន។

# ការការពារទិន្នន័យក្នុងបរិបទ ជនជាតិដើមភាគតិចនៅកម្ពុជា

លោកស្រី Erica Irene Daes អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ បានមានប្រសាសន៍ថា «ការចុះខ្សោយបន្តិចម្តងៗ នៃសង្គមជនជាតិដើមភាគតិច អាចបណ្តាលមកពីកង្វះការទទួលស្គាល់នូវទំនាក់ទំនងដ៏ជ្រាលជ្រៅរបស់ជនជាតិដើមភាគតិចជាមួយនឹងទឹកដីដែនដី និងធនធានរបស់ពួកគេ» ដែលបង្ហាញពីការគំរាមកំហែង និងបញ្ហាប្រឈមគួរឱ្យព្រួយបារម្ភចំពោះសហគមន៍ជនជាតិដើមភាគតិនៅជុំវិញពិភពលោក។[១] ការគំរាមកំហែងកាន់តែខ្លាំងឡើងៗ ចំពោះសហគមន៍ជនជាតិដើមភាគតិច បានជំរុញឱ្យមានការផ្តោតយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ លើសិទ្ធិជនជាតិដើមនៅក្នុងច្បាប់ និងគោលនយោបាយអន្តរជាតិ «នៅពេលដែលពិភពលោកស្វះស្វែងការពារវប្បធម៌ និងជីវភាពរស់នៅដ៏ប្រពៃ ក៏ដូចជាសិទ្ធិបុគ្គលដែលបានរងផលប៉ះពាល់»។[២]

តួនាទីស្នូលរបស់រដ្ឋក្នុងការការពារជនជាតិដើមភាគតិចដែលងាយរងគ្រោះទាំងនេះ បានក្លាយជាចំណុចផ្តោតនៃការជជែកដេញដោលជាអន្តរជាតិ។ ក្រុមការងារអន្តរជាតិទទួលបន្ទុកកិច្ចការជនជាតិដើមភាគតិច (IWGIA) បានលើកឡើងថា ជនជាតិដើមភាគតិចនៅជុំវិញពិភពលោក «នៅតែស្ថិតនៅក្រៅរង្វង់សង្គម៖ ពួកគេកាន់តែមានភាពក្រីក្រ ទទួលបានការអប់រំតិចតួច ស្លាប់ទាំងវ័យក្មេង ទំនងជាធ្វើអត្តឃាតកាន់តែច្រើនឡើង ហើយជាទូទៅមានស្ថានភាពសុខភាពទន់ខ្សោយជាងប្រជាជនដទៃទៀត»។[៣] ករណីនេះអនុវត្តចំពោះបរិបទកម្ពុជា «ដែលក្នុងនោះការរំលោភសិទ្ធិដីធ្លីជាប្រព័ន្ធគឺជាការបំពានសិទ្ធិមនុស្សដែលបច្ចុប្បន្នកំពុងតែមានការរីករាលដាលខ្លាំងបំផុត។ ជាពិសេស ជនជាតិដើមភាគតិចបាននិងកំពុងបាត់បង់ដីធ្លីយ៉ាងច្រើនគួរឱ្យព្រួយបារម្ភ ដោយសារតែការកាប់ព្រៃឈើទ្រង់ទ្រាយធំ ការទាញយកធនធាន គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជាការសាងសង់ទំនប់ និងបំពង់បង្ហូរប្រេង និងសម្បទានដីសម្រាប់ធ្វើកសិ-ពាណិជ្ជកម្ម»។[៤] យោងតាមសមិទ្ធផលការងាររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បានបង្ហាញថា មានការប្រឹងប្រែងតស៊ូដើម្បីអនុញ្ញាតឱ្យជនជាតិដើមភាគតិច ប្រើប្រាស់គោលនយោបាយថ្មីៗ ដើម្បីការពារកម្មសិទ្ធិដីសមូហភាពរបស់ពួកគេ៖ «ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចចំនួន ៤.៥៨២ នៅកម្ពុជា មានតែសហគមន៍ជនជាតិដើមភាគតិចចំនួន ១១៣ ប៉ុណ្ណោះដែលអាចបំពេញដំណើរការចុះបញ្ជីដីសមូហភាពរបស់ខ្លួន»។[៥] ប្រសិទ្ធភាពនៃការការពារក្រោមច្បាប់ភូមិបាល គឺស្ទើរតែគ្មានទាល់តែសោះ។

ប្រជាពលរដ្ឋខ្មែរមានចំនួនស្មើនឹង ៩០% នៃប្រជាជនកម្ពុជា បន្ទាប់មកជនជាតិវៀតណាម ៥% នៅសល់ ៥% ទៀត ជាជនជាតិចិន ចាម (ភាគច្រើនជាសហគមន៍ឥស្លាម) និងជនជាតិដើមភាគតិច ឬហៅថាខ្មែរលើ។[៦] យោងតាមការសិក្សាដំបូងដែលដឹកនាំដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩២ បានប៉ាន់ប្រមាណថាមានជនជាតិដើមភាគតិចចំនួន ១២០.០០០ នាក់នៅក្នុងប្រទេសកម្ពុជា ខណៈដែលអង្គការផ្សេងទៀតបានបញ្ជាក់ថាមានចំនួនប្រហែល ២០០.០០០ នាក់ក្នុងឆ្នាំ២០០៨។[៧] យោងតាមក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ (Minority Rights Group International) មានជនជាតិដើមភាគតិចចំនួន ៤០០.០០០នាក់ ក្នុងឆ្នាំ២០១៧ ស្មើនឹង ២ - ៣% នៃប្រជាជនកម្ពុជាសរុប។[៨]

ទោះបីជាជនជាតិដើមភាគតិចសរុបចំនួន ២៤ អំបូរ[៩] ត្រូវបានគេកំណត់អត្តសញ្ញាណក៏ដោយ ប៉ុន្តែមានតែ ១៧ ប៉ុណ្ណោះដែលត្រូវបានច្បាប់ទទួលស្គាល់។ ក្រុមជនជាតិដើមភាគតិចរួមមាន ជនជាតិព្រៅ ជង ចារ៉ាយ

កាចក់ កាវ៉ែត ខិ ខោញ កួយ គ្រឹង ក្រោល ព្នង ល្មិន លុន មិល ព័រ រដែ រអង ស្ទច សំរែ ស្ទួយ ស្ទូង ស្មៀង ថ្នួន និងទំពួន ដែលនៅរាយប៉ាយនៅទូទាំង ១៥ ខេត្ត ដែលភាគច្រើននៅតំបន់ខ្ពង់រាបខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ។ អ្នកជំនាញបានរកឃើញថាជនជាតិដើមភាគតិចមានភាសាចំនួន ១៩ ខុសៗ គ្នានៅក្នុងប្រទេសកម្ពុជា[១០] ហើយបានបញ្ជាក់ថា ប្រជាជនទាំងនេះកំពុងរស់នៅលើផ្ទៃដីជិត ៤ លានហិកតាក្នុងតំបន់ព្រៃស្រោង និងព្រៃល្បោះ។[១១] ការរស់នៅរបស់ជនជាតិដើមភាគតិចមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងប្រព័ន្ធប្រើប្រាស់ដីរបស់ពួកគេ និងលទ្ធភាពទទួលបានធនធានព្រៃឈើ។ បច្ចេកទេសប្រពៃណីរបស់ពួកគេរួមមានការអនុវត្ត "ការធ្វើកសិកម្មវិលជុំ(ពនេចរ)និងការចិញ្ចឹមសត្វការប្រមូលផលផ្តៅនិងវល្លិជ័រក្រវាញ និងទឹកឃ្មុំនៅក្នុងព្រៃ។ ការងារតម្បាញគឺជាប្រភពចំណូលដ៏សំខាន់មួយទៀត។ ប្រភពចំណូលមួយចំនួនអាស្រ័យទៅលើទីតាំង ដូចជាការជីករ៉ែត្បូងថ្មមានតម្លៃនៅក្រៅក្រុងបានលុងក្នុងខេត្តរតនគិរី»។[១២]

យ៉ាងណាក៏ដោយ រហូតមកដល់សព្វថ្ងៃនេះ មិនទាន់មានការកំណត់និយមន័យផ្លូវការនៃពាក្យ«ជនជាតិដើមភាគតិច» ដើម្បីផ្តល់សិទ្ធិ និងការការពារពិសេសដល់ប្រជាជនទាំងនេះនៅក្នុងប្រទេសកម្ពុជានោះទេ។ មានការបរិយាយដ៏មានប្រយោជន៍នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ (ផ្នែកទី ២ នៃជំពូកទី ៣) អំពី «អចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច» ដែលកំណត់និយមន័យសហគមន៍ជនជាតិដើមភាគតិចក្នុងន័យទូលាយថាជា «ក្រុមប្រជាជនរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាជិករស់នៅរួបរួមជាតិសាសន៍ សង្គម វប្បធម៌ និងសេដ្ឋកិច្ច និងមានជីវភាពរស់នៅបែបប្រពៃណី ហើយប្រកបការងារដាំដុះលើដីជាកម្មសិទ្ធិរបស់ពួកគេស្របតាមច្បាប់ទម្លាប់នៃការប្រើប្រាស់សមូហភាព»។[១៣]ច្បាប់កម្ពុជាប្រើពាក្យជាច្រើន រួមមាន «សហគមន៍ជនជាតិដើមភាគតិច» «ជនជាតិដើមភាគតិច» និង «ជនជាតិរស់នៅតាមតំបន់ខ្ពង់រាប» «កុលសម្ព័ន្ធភ្នំ» «ប្រជាជនរស់នៅតំបន់ខ្ពង់រាប» និង «ខ្មែរលើ» សំដៅដល់ជនជាតិដើមភាគតិច។ ប្រជាជនទាំងនេះតែងហៅខ្លួនឯងថា ជនជាតិ។

កង្វះឋានៈផ្លូវច្បាប់ដើម្បីការពារជនជាតិដើមភាគតិចនៅក្នុងច្បាប់របស់កម្ពុជា នៅតែជាបញ្ហាដ៏ចម្បង ដោយសារតែសហគមន៍ ដែលរស់នៅរប៉ាត់រប៉ាយទាំងនេះកំពុងតែប្រឈមមុខនឹងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរមកលើជីវភាពរស់នៅ និងដីធ្លី និងសហគមន៍របស់ពួកគេ។ ជាប្រវត្តិសាស្ត្រកន្លងមកនេះ មានចលនាសិទ្ធិជនជាតិដើមភាគតិចបានចាប់ផ្តើមឡើងនៅចុងទសវត្សរ៍ឆ្នាំ១៩៩០ ហើយបន្តកើនឡើងដល់សព្វថ្ងៃនេះ។ ទោះជាយ៉ាងណាជំហររបស់ពួកគេហាក់ដូចជាទទួលរងនូវ «ការបង្ក្រាបនាពេលថ្មីៗ នេះពីសំណាក់រដ្ឋាភិបាលមកលើគណបក្សនយោបាយ»[១៤] រួមទាំងការរំលាយគណបក្សប្រឆាំងដ៏ធំមួយពីសំណាក់តុលាការកំពូល ដែលអនុញ្ញាតឱ្យគណបក្សប្រជាជនកម្ពុជាគ្រប់គ្រងរដ្ឋាភិបាលក្រោមគណបក្សតែមួយប្រកបដោយប្រសិទ្ធភាព។ ករណីពាក់ព័ន្ធផងដែរគឺការចាប់ខ្លួនអ្នកនយោបាយគណបក្សប្រឆាំងជាច្រើននាក់ដាក់ពន្ធនាគារ និងការដាក់បម្រាមទូទៅក្នុងការចូលរួមសកម្មភាពនយោបាយរយៈពេល ៥ ឆ្នាំ ចំពោះសមាជិកគណបក្សសង្គ្រោះជាតិចំនួន ១០៧ នាក់ក្នុងចំណោម ១១៨ នាក់។[១៥]

ជាអកុសល ចលនាសិទ្ធិជនជាតិដើមភាគតិចបានក្លាយទៅជាទម្រង់មួយនៃ «ការប្រឆាំង» ចំពោះគណបក្សកាន់អំណាច។ ម្យ៉ាង ការទាមទារឱ្យមានការការពារដីធ្លី និងការពារព្រៃឈើ ទទួលបានការគាំទ្រពីអ្នកបរិស្ថាន និងជនជាតិដើមភាគតិច។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលកំពុងជួយឱ្យមានកំណើនសេដ្ឋកិច្ចជាតិតាមរយៈការអភិវឌ្ឍរបស់ក្រុមហ៊ុនធំៗ ដែលជួនកាលនាំឱ្យមានការកាប់បំផ្លាញព្រៃឈើ។ តាមរយៈព្រឹត្តិការណ៍ក្នុងស្រុកមួយចំនួន បង្ហាញឱ្យឃើញកាន់តែច្បាស់ពីការតស៊ូរវាងតំណាងជនជនជាតិដើមភាគតិច និងរដ្ឋាភិបាល ដោយសារតែមានការគំរាមកំហែង និងអំពើហិង្សា និងការចាប់ខ្លួនតំណាងជនជាតិដើមភាគតិចមួយចំនួនតាមអំពើចិត្ត ដូចដែលយើងអាចឃើញស្រាប់ ជាតួយ៉ាង ការចាប់ខ្លួនសកម្មជន ជនជាតិកួយ។[១៦] តាមការបញ្ជាក់របស់ក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ (Minority Rights Group International) «កម្ពុជាគឺជាកន្លែងគ្រោះថ្នាក់បំផុតមួយក្នុងនាមជាអ្នកការពារសិទ្ធិបរិស្ថាន ដោយមនុស្សជាច្រើនត្រូវបានគេសម្លាប់ដោយសារតែបំពេញការងាររបស់ខ្លួនក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រួមទាំងសកម្មជនជនជាតិដើមភាគតិចផងដែរ»។[១៧]

បញ្ហាប្រឈមចម្បងសម្រាប់ចលនានេះកើតចេញពីការរើសអើង និងការបង្ខំឱ្យផ្លាស់ទីលំនៅចេញពីទឹកដីរបស់ខ្លួនដែលជំរុញឱ្យមានការផុតពូជអំបូររបស់ពួកគេ។ ទឹកដីដែលជនជាតិដើមភាគតិចធ្លាប់រស់នៅជាប្រវត្តិសាស្ត្រកំពុងត្រូវបានគេផ្លាស់ប្តូរ ក្នុងគោលបំណងទាញយកធនធានរ៉ែ និងអភិវឌ្ឍ ហើយ "សកម្មភាពទាំងនេះបានជំរុញតាមរយៈការធ្វើអាជីវកម្មជាបន្តបន្ទាប់រវាងរដ្ឋ និងក្រុមហ៊ុនឆ្លងដែនដើម្បីទាញយកធនធាន/កែច្នៃធនធាន (ភាគច្រើនឈើ រ៉ែ ថាមពលវារីអគ្គិសនី និងកសិ-ពាណិជ្ជកម្ម) គួបផ្សំជាមួយនឹងកំណើននៃការធ្វើចំណាកស្រុកចូលមកពីតំបន់ផ្សេងៗនៃប្រទេស"[១៨] ដូចបានរៀបរាប់ដោយក្រុមការងារអន្តរជាតិទទួលបន្ទុកកិច្ចការជនជាតិដើមភាគតិច (IWGIA)។ ការជជែកដេញដោលនេះបានបង្ហាញថាជាការប្រជែងគ្នារវាងផលប្រយោជន៍ជាតិដើម្បីថាមពល និងកំណើនសេដ្ឋកិច្ច ជាមួយនឹងការអភិរក្សជម្រករបស់ជនជាតិដើមភាគតិច។

ការងាររបស់អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធអភិវឌ្ឍន៍ផ្សេងទៀត គឺជាគន្លឹះក្នុងការចងក្រងព័ត៌មានអំពីសហគមន៍ជនជាតិដើមភាគតិច លើកកម្ពស់ការយល់ដឹងអំពីស្ថានភាពរបស់ពួកគេ ក៏ដូចជាលើកកម្ពស់សិទ្ធិ និងជីវភាពរស់នៅរបស់ពួកគេ។ អង្គការទិន្នន័យអំពីការអភិវឌ្ឍក៏ផ្តល់សិទ្ធិអំណាច និងគាំទ្រដល់សំឡេងជនជាតិដើមភាគតិច តាមរយៈការគូសផែនទី ការប្រមូលទិន្នន័យ ក៏ដូចជា ការបង្រៀន និងលើកកម្ពស់សិទ្ធិទទួលបានការប្រើប្រាស់ស្របច្បាប់នៅនឹងកន្លែងក្រោមច្បាប់ភូមិបាល។[១៩] ដោយសារតែមានអ្នកជំនាញនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលទើបអាចផ្តល់នូវទិដ្ឋភាពទូទៅច្បាស់លាស់អំពីសម្បទានដី សេដ្ឋកិច្ច សម្បទានរ៉ែ និងទំនប់វារីអគ្គិសនី ការរំលោភយកដី ការកាប់បំផ្លាញព្រៃឈើ និងការកាប់ឈើខុសច្បាប់ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ក្រុមជនជាតិដើមភាគតិច។[២០]

ពន្លឺនៃបញ្ហានេះគឺការផ្លាស់ប្តូរហ្គេមសម្រាប់សហគមន៍ជនជាតិដើមភាគតិច។ សហគមន៍ជនជាតិដើមភាគតិចចំនួន ១៧ ដែលភាគច្រើនជាជនជាតិទំពួន ចារ៉ាយ កាចក់ និងគ្រឹងក្នុងខេត្តរតនគិរី បានប្តឹងតវ៉ាថាដីរបស់ពួកគេត្រូវបានផ្តល់ជាសម្បទានដីសេដ្ឋកិច្ច (ELC) សម្រាប់ក្រុមហ៊ុនចម្ការកៅស៊ូមកពីប្រទេសវៀតណាម តាមរយៈហិរញ្ញប្បទានដែលជាប់ពាក់ព័ន្ធជាមួយនឹងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោក (IFC)។ ដោយមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការជនជាតិដើមភាគតិច ទើបសហគមន៍ទាំងនេះបានបង្កើតបណ្តាញទំនាក់ទំនងជាមួយការិយាល័យប្រជាពលរដ្ឋរបស់ទីប្រឹក្សាផ្នែកអនុលោមភាពរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិក្នុងឆ្នាំ២០១៣-២០១៤។[២១] ជាលទ្ធផលនៃការចរចាដែលបានធ្វើឡើងនៅក្នុងឆ្នាំ២០១៥ រវាងភាគីនានា និងដោយមានការសម្រុះសម្រួលពីសំណាក់ការិយាល័យប្រជាពលរដ្ឋ ក្រុមហ៊ុនចម្ការកៅស៊ូបានយល់ព្រមសម្របសម្រួលដំណើរការបណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ចំនួន ១១ និងផ្តល់ដំណោះស្រាយផ្សេងៗ។[២២]

ថ្មីៗ នេះក៏មានការពង្រីកវិសាលភាពនៃបទប្បញ្ញត្តិ ដើម្បីការពារជនជាតិដើមភាគតិចទាំងនេះនៅក្នុងប្រទេសកម្ពុជាផងដែរ។ ក្នុងឆ្នាំ២០០៧ រដ្ឋាភិបាលបានអនុម័តសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ដោយគ្មានឧបម្រុងដែលត្រូវបានផ្តល់សច្ចាប័នរួមជាមួយនឹងកិច្ចព្រមព្រៀងផ្សេងទៀតពោលគឺ ICERD,[២៣] CEDAW,[២៤] ICCPR,[២៥] ICESCR,[២៦] CDB,[២៧] និង CRC[២៨]។ ទន្ទឹមនឹងនេះ កម្ពុជាបានទទួលយកអនុសាសន៍មួយដែលបង្ហាញពីភាពចាំបាច់ "ក្នុងការបង្កើនវិធានការដោះស្រាយការបណ្តេញចេញដោយខុសច្បាប់ពីដី [របស់] ជនជាតិដើមភាគតិច និងពិចារណាពង្រឹងក្របខណ្ឌច្បាប់ស្របតាមបទដ្ឋានអន្តរជាតិ" ក្នុងអំឡុងពេលនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ចុងក្រោយរបស់ខ្លួនក្នុងអំឡុងឆ្នាំ ២០១៣។ ទោះជាយ៉ាងណា ចាប់តាំងពីពេលនោះមក គេពុំឃើញមានលទ្ធផលជាក់ស្តែងណាមួយដើម្បីទប់ស្កាត់ការរើសអើងនិងដោះស្រាយអសន្តិសុខដីធ្លីរបស់ជនជាតិដើមភាគតិចឡើយ។

នៅថ្នាក់ជាតិ ច្បាប់កម្ពុជាត្រូវបានសន្មត់ថា[២៩] បានបង្កើតបទប្បញ្ញត្តិ និងគោលនយោបាយចេញពីច្បាប់ភូមិបាល និងច្បាប់ស្តីពីធនធានធម្មជាតិ ដើម្បីផ្តល់សិទ្ធិដល់សហគមន៍មូលដ្ឋាន។ ក្តីសង្ឃឹមដែលថាច្បាប់

ភូមិបាលឆ្នាំ២០០១[៣០] និងច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ នឹងឈានដល់ដំណោះស្រាយដ៏សំខាន់ ក្នុងការការពារដីធ្លីរបស់ជនជាតិដើមភាគតិច តាមរយៈការផ្តល់បណ្ណកម្មសិទ្ធិដីសមូហភាពក៏បានសាបរលាបទៅវិញក្នុងឆ្នាំ២០១៨។ នៅចុងឆ្នាំ ២០១៨ មានសហគមន៍ជនជាតិដើមភាគតិចតែមួយចំនួនប៉ុណ្ណោះ ដែលបានទទួលបណ្ណកម្មសិទ្ធិ។[៣១] អាស្រ័យហេតុនេះ វឌ្ឍនភាពផ្នែកច្បាប់មិនបានស្តែងចេញទៅជាសកម្មភាពពិត ឬការធ្វើឱ្យប្រសើរឡើងពិតប្រាកដនូវសិទ្ធិជនជាតិដើមភាគតិចនោះទេ។ វាអាចត្រូវបានគេមើលឃើញថាបទប្បញ្ញត្តិធ្វើឱ្យការការពារសហគមន៍ទាំងនេះកាន់តែលំបាកខ្លាំងឡើង ដោយហេតុថា ជាតួយ៉ាង "គោលនយោបាយ និងអនុក្រឹត្យជាបន្តបន្ទាប់ស្តីពីការចុះបញ្ជីសិទ្ធិដីសមូហភាពរបស់ជនជាតិដើមភាគតិចបានកំណត់ពីការបង្កើតសហគមន៍ជានីតិបុគ្គល សម្រាប់ជាលក្ខខណ្ឌមួយក្នុងការទទួលបានបណ្ណកម្មសិទ្ធិសមូហភាព"។[៣២] ទោះបីជាមានយន្តការច្បាប់នេះក៏ដោយ ក៏នៅមានចំណុចខ្វះខាតយ៉ាងច្បាស់ក្នុងការអនុវត្ត និងមិនមានការតាមដានច្បាស់លាស់។ ជាចុងក្រោយ រដ្ឋាភិបាលនៅតែបន្តផ្តល់ "ដីសម្បទានសេដ្ឋកិច្ចដល់ចម្ការកៅស៊ូ ដោយមិនមានការពិគ្រោះយោបល់ដោយសេរី ឬការយល់ព្រមត្រឹមត្រូវជាមុនពីសហគមន៍ជនជាតិដើមភាគតិច"។[៣៣]

គោលនយោបាយទូលំទូលាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ពោលគឺគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (NPDIP) ត្រូវបានអនុម័តក្នុងឆ្នាំ២០០៩។[៣៤] គោលបំណងនៃគោលនយោបាយនេះគឺនៅជុំវិញភាពចាំបាច់ក្នុងការលើកកម្ពស់ «កម្រិតជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច និងលើកកម្ពស់គុណភាពជីវិតរបស់ពួកគេ។ គោលនយោបាយនេះផ្តោតលើវិស័យអភិវឌ្ឍន៍ចំនួនដប់ រួមមាន វិស័យវប្បធម៌ អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីធ្លី កសិកម្ម និងធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល»។[៣៥]

ដោយមើលឃើញពីស្ថានភាពជាប់គាំងនេះ អង្គការមិនមែនរដ្ឋាភិបាលជាច្រើន[៣៦] បានមកជួយជនជាតិដើមភាគតិចគោលដៅទាំងនេះ ដើម្បីរក្សាដីធ្លី និងបែបផែននៃការរស់នៅរបស់ពួកគេ។ សមាគមបានផ្តល់ការគាំទ្រ ប្រឹក្សា ដាក់ពាក្យបណ្តឹងប្តឹងរដ្ឋ និងប្រមូលព័ត៌មានដើម្បីបង្ហាញជាសាធារណៈនូវការប្រយុទ្ធតស៊ូរបស់ជនជាតិដើមភាគតិចនៅកម្ពុជា។ តួនាទីរបស់ពួកគេមានសារៈសំខាន់ណាស់ក្នុងដំណើរការផ្តល់ការការពារដល់ប្រជាជនទាំងនេះ។

ក្នុងចំណោមបញ្ហាប្រឈមផ្សេងៗ ក្នុងការចុះបញ្ជីដីធ្លីសម្រាប់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ការប្រមូលទិន្នន័យគឺជាបញ្ហាមួយដែលបានលើកឡើងទាក់ទងនឹងការកាន់កាប់កម្មសិទ្ធិ និងប្រើប្រាស់ព័ត៌មាន។ បញ្ហានេះកើតឡើងដំបូងតាមរយៈការងាររបស់អង្គការមិនមែនរដ្ឋាភិបាលដែលជួយដល់ជនជាតិដើមភាគតិច។ ការប្រមូលទិន្នន័យដែលដំណើរការដោយអង្គការមិនមែន រដ្ឋាភិបាល ដើម្បីកសាងស្ថិតិអំពីស្ថានភាពជនជាតិដើមភាគតិច ក៏ដូចជានៅក្នុងដំណើរការចុះបញ្ជីដីធ្លីដែលបញ្ជូនទៅរដ្ឋបាលកណ្តាល បានក្លាយជាកង្វល់ដ៏សើបមួយចំពោះជនជាតិដើមភាគតិច។ ជនជាតិដើមភាគតិចបានចាប់ផ្តើមយល់ដឹងពីបញ្ហាសំខាន់នៃការការពារទិន្នន័យ ហើយបច្ចុប្បន្នកំពុងមានការព្រួយបារម្ភថាការប្រមូលទិន្នន័យ សូម្បីតែនៅក្នុងដំណើរការចុះបញ្ជីដីធ្លីក៏ដោយ ក៏អាចប្រែត្រលប់មកជាការប្រឆាំងនឹងពួកគេវិញ ដែលព័ត៌មាន និងទិន្នន័យទាំងនោះនឹងអនុញ្ញាតឱ្យពាណិជ្ជករ និងវិនិយោគិនកំណត់គោលដៅទីតាំងជុំវិញដីជនជាតិដើមភាគតិច និងកាត់បន្ថយជម្រកធម្មជាតិរបស់ប្រជាជនទាំងនេះ តាមរយៈការកាប់បំផ្លាញព្រៃឈើស្របច្បាប់ដើម្បីកំណត់ព្រំប្រទល់ថ្មីស្របតាមច្បាប់ភូមិបាល។

បញ្ហាប្រឈមទាំងនេះបង្កើតឱ្យមានការជជែកវែកញែកជាមូលដ្ឋានលើបទប្បញ្ញត្តិបច្ចុប្បន្ន ស្តីពីការការពារទិន្នន័យ ដែលអាចផ្តល់ប្រយោជន៍ដល់ជនជាតិដើមភាគតិច និងរារាំងការបំផ្លិចបំផ្លាញតំបន់របស់ពួកគេពីសំណាក់វិនិយោគិន។ តើមានការការពារទិន្នន័យបែបណាសម្រាប់ជនជាតិដើមភាគតិច និងទឹកដីរបស់ពួកគេ?

ជារួម រាល់សកម្មភាពដឹកនាំដោយរដ្ឋាភិបាលបានផ្តោតជាអាទិភាពលើរឿងនយោបាយដោយមិនគិតគូរអំពីក្របខណ្ឌច្បាប់ច្បាស់លាស់ណាមួយ ដែលផ្តល់ប្រយោជន៍ដល់ជនជាតិដើមភាគតិច។ បញ្ហាជុំវិញការការពារ

ទិន្នន័យឆ្លុះបញ្ចាំងពីបញ្ហាជាក់ស្តែងដែលជនជាតិដើមភាគតិចកំពុងជួបប្រទះនាពេលបច្ចុប្បន្ន។ ទោះបីជាការប្រមូលទិន្នន័យជនជាតិដើមភាគតិចជួយគាំទ្រដល់ការការពារផ្លូវច្បាប់ និងសមត្ថភាពរបស់ពួកគេក្នុងការធានាបាននូវកម្មសិទ្ធិដីធ្លីរបស់ពួកគេក៏ដោយ ប៉ុន្តែទន្ទឹមនឹងនោះ ទិន្នន័យក៏អាចបង្កផលប៉ះពាល់ដល់ពួកគេផងដែរ។ ជាការពិតណាស់ ការប្រមូលទិន្នន័យបង្ហាញពីហានិភ័យមួយចំនួនទាក់ទងនឹងឯកជនភាព និងការការពារទិន្នន័យសម្រាប់ជនជាតិដើមភាគតិចទាំងនេះ។

កង្វល់ចម្បងដែលកើតឡើង គឺការគំរាមកំហែងជុំវិញការចុះបញ្ជីដោយផ្ទាល់។ វាអាចប៉ះពាល់ដល់ទិន្នន័យផ្ទាល់ខ្លួនរបស់ជនជាតិដើមភាគតិច ដែលផ្តល់ព័ត៌មានច្បាស់លាស់ដល់វិនិយោគិន ដើម្បីបន្តការអភិវឌ្ឍដែលបង្កគ្រោះថ្នាក់ដល់ជីវភាពរស់នៅ និងទីជម្រករបស់ជនជាតិដើមភាគតិច។

ការវិវត្តថ្មីៗនៃក្របខណ្ឌច្បាប់ជុំវិញការការពារទិន្នន័យនៅក្នុងប្រទេសកម្ពុជា អាចនាំមកនូវការការពារផ្នែកច្បាប់ដើម្បីជាប្រយោជន៍ដល់ជនជាតិដើមភាគតិច។ ជាអកុសលឧបករណ៍ផ្លូវច្បាប់ទាំងនេះត្រូវបានបង្ហាញយ៉ាងច្បាស់ថាគ្មានប្រសិទ្ធភាពនិងមិនផ្តល់ការការពារត្រឹមត្រូវដល់ជនជាតិដើមភាគតិចដែលបានរងការគំរាមកំហែង។ ដូច្នេះ តាមរយៈសមិទ្ធផលនេះបានរកឃើញការគំរាមកំហែងជាច្រើនជុំវិញការប្រមូលទិន្នន័យ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ការប្រយុទ្ធតស៊ូដើម្បីទទួលបានការចុះបញ្ជីដីធ្លី (II) ដែលតំណាងឱ្យបញ្ហាប្រឈមដ៏ស្មុគ្រស្មាញជុំវិញបញ្ហាទិន្នន័យនៅក្នុងប្រទេសកម្ពុជា (I) ។ ក្របខណ្ឌច្បាប់កម្ពុជាស្តីពីការការពារទិន្នន័យកំពុងប្រឈមនឹងបញ្ហាយ៉ាងធ្ងន់ធ្ងរ។ អត្ថបទនេះនឹងផ្តល់ការវិភាគខ្លីៗ អំពីខ្លឹមសារទាក់ទងនៃច្បាប់ថ្មីៗ របស់កម្ពុជាស្តីពីការការពារទិន្នន័យ (III) ដែលថ្ងៃណាមួយអាចជាប្រភពនៃក្តីសង្ឃឹមសម្រាប់ការពារជនជាតិដើមភាគតិច ប៉ុន្តែមិនទាន់បានឆ្លើយតបនឹងវិបត្តិបច្ចុប្បន្ននៅឡើយ។

# ១. ការកើនឡើងនូវបញ្ហាទិន្នន័យ និងករណីជនជាតិដើមភាគតិចនៅកម្ពុជា

ដើម្បីបញ្ជាក់អំពីបញ្ហាប្រឈមជុំវិញទិន្នន័យក្នុងករណីជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា រឿងសំខាន់ដំបូងគឺត្រូវមានការក្រឡេកមើលទិដ្ឋភាពទូទៅនៃគោលគំនិតអំពីទិន្នន័យទាក់ទងនឹងឯកជនភាព (ក) ដែលនាំឱ្យការយល់ដឹងកាន់តែច្បាស់អំពីករណីជាក់លាក់នៃការប្រមូលទិន្នន័យប្រជាជន (ខ) របស់ជនជាតិដើមភាគតិច។

## ក. ការក្រឡេកមើលទិដ្ឋភាពទូទៅនៃគោលគំនិតអំពីទិន្នន័យទាក់ទងនឹងឯកជនភាព

ការប្រមូលទិន្នន័យអាចតំណាងឱ្យប្រភពនៃគ្រោះថ្នាក់ចំពោះឯកជនភាពនិងការការពារទិន្នន័យ។ នៅក្នុងបរិបទជនជាតិដើមភាគតិចដែលឆ្លងកាត់នីតិវិធីចុះបញ្ជីដីធ្លីក្នុងប្រទេសកម្ពុជា ការប្រមូលទិន្នន័យត្រូវបានចាត់ទុកថាជាការគំរាមកំហែងមួយចំពោះឯកជនភាពរបស់សហគមន៍ ដោយសារវាត្រូវផ្តល់ព័ត៌មានផ្ទាល់ខ្លួនតាមរយៈទម្រង់ពាក្យសុំ និងការស្ទង់មតិ។ ព័ត៌មានដែលត្រូវផ្តល់រួមមាន ឈ្មោះ ភេទ ភាសា សាសនា ជនជាតិ ទីតាំងដីលម្អិតដែលពួកគេទាមទារ និងចំនួនប្រជាជនរស់នៅលើដីនោះ។ លើសពីនេះ មន្ត្រីជំនាញនឹងត្រូវបានចាត់បញ្ជូនឱ្យចុះទៅពិនិត្យដីជាក់ស្តែង។ ការវិភាគលម្អិតលើនីតិវិធី និងបញ្ហាឯកជនភាពនឹងផ្តល់ជូននៅពេលក្រោយ ប៉ុន្តែជាដំបូងយើងត្រូវស្វែងយល់អំពីគោលគំនិតខុសៗគ្នាជុំវិញឯកជនភាព និងការការពារទិន្នន័យ។

ជាក់ស្តែងណាស់ នៅក្នុងពិភពមួយដែលជំរុញល្បឿនបដិវត្តន៍ទិន្នន័យសកលបើនិយាយអំពីគម្រោងទិន្នន័យធំៗ និងបញ្ញានិម្មិត ការប្រមូល ដំណើរការ និងផ្ទុកទិន្នន័យ គឺជាចំណុចសំខាន់នៃលំហូរព័ត៌មានរបស់យើង។ នេះគឺជាកន្លែងការពារទិន្នន័យ និងសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានឯកជនភាព។ ឯកជនភាព គឺជាសិទ្ធិមនុស្សមួយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅក្នុងមាត្រា ១២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ដែលរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាក្នុងឆ្នាំ ១៩៩៣។សេចក្តីប្រកាសនេះចែងថា «[គ្មាន] ជនណាម្នាក់ត្រូវទទួលរងនូវការជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជន ក្រុមគ្រួសារ ផ្ទះសម្បែង ឬការឆ្លើយឆ្លងរបស់ខ្លួនឡើយ .... ជនគ្រប់រូបមានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ។»[៣៧]

ឫសគល់ទូទៅនៃការការពារឯកជនភាព និងទិន្នន័យត្រូវបានបញ្ជាក់រួចហើយដោយអតីត អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ នៅក្នុងរបាយការណ៍ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពនៃគំនិត និងការសម្តែងមតិ៖ «ការការពារទិន្នន័យផ្ទាល់ខ្លួនតំណាងឱ្យទម្រង់ពិសេសមួយនៃការគោរពសិទ្ធិឯកជនភាព។[៣៨]

ផ្តើមពីទស្សនៈជាក់ស្តែង យើងអាចនិយាយបានថា ឯកជនភាព «តាមរចនាបថទាមទារឱ្យមានការពិចារណាលើឯកជនភាពនៅក្នុងដំណើរការអភិវឌ្ឍផលិតផល ឬសេវាកម្មណាមួយ» ដែលផ្ទុយពីឯកជនភាពតាមលំនាំដើមដែល ទាមទារឱ្យមានការកំណត់លំនាំដើមដែលអនុញ្ញាតឱ្យអតិថិជនសម្រេចថាតើពួកគេចង់ចែករំលែកវាជាមួយអ្នកដទៃកម្រិតណាដែរ»។[៣៩] ក្នុងការអនុវត្តជាក់ស្តែងគួរតែប្រែប្រួលទៅតាមប្រភេទនៃការយល់ព្រមរបស់អ្នកប្រើប្រាស់ ដែលចែករំលែកទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេ។

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់កម្ពុជាកំណត់ទិន្នន័យថាជា «ក្រុមលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិក»។[៤០] ត្រង់ចំណុចនេះ យើងទទួលស្គាល់ទិន្នន័យជាព័ត៌មានដែលបានកត់ត្រារួមទាំងទិន្នន័យបច្ចេកទេស និងកម្មវិធីកុំព្យូទ័រ។ ទោះជាយ៉ាងណា ពាក្យនេះមិនអនុវត្តចំពោះព័ត៌មានដែលជាយថាហេតុនៃការគ្រប់គ្រងកិច្ចសន្យា ដូចជាព័ត៌មានហិរញ្ញវត្ថុ រដ្ឋបាល ថ្លៃដើម ឬព័ត៌មានកំណត់តម្លៃ ឬព័ត៌មានគ្រប់គ្រងនោះទេ។[៤១] វាក៏ជាការសំខាន់ផងដែរ ដែលពិចារណាថារាល់ទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិតអាចត្រូវបានគេមើលឃើញថាជា «ទិន្នន័យផ្ទាល់ខ្លួន»។ ដូច្នេះជាទូទៅ «ទិន្នន័យធម្មតាដូចជាឈ្មោះពេញ លេខអត្តសញ្ញាណប័ណ្ណ លេខលិខិតឆ្លងដែន រូបថត រូបភាព លេខទូរស័ព្ទ អាសយដ្ឋាន អ៊ីម៉ែលផ្ទាល់ខ្លួន អាសយដ្ឋានជនជាតិដើមភាគតិច និងឧបករណ៍កំណត់អត្តសញ្ញាណបណ្តាញផ្សេងទៀត អាចជាទិន្នន័យផ្ទាល់ខ្លួនក្រោមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក»។[៤២]

វាមានប្រយោជន៍ក្នុងការបែងចែកប្រភេទទិន្នន័យផ្សេងៗគ្នាដោយសារទិន្នន័យផ្ទាល់ខ្លួនមានរបបជាក់លាក់ដែលត្រូវបានច្បាប់ការពារ។ តាមវិធីនេះ គេអាចកំណត់បានថាតើការទាមទារសិទ្ធិឯកជនភាព និងសិទ្ធិការពារទិន្នន័យរបស់សហគមន៍ជនជាតិដើមភាគតិចអាចត្រូវបានរំលោភឬទេ។ បន្ទាប់មក គោលគំនិតអំពីទិន្នន័យផ្ទាល់ខ្លួនគឺទាក់ទងទៅនឹងអ្នកនៅរស់ដែលអាចឱ្យគេកំណត់អត្តសញ្ញាណ ឬអ្នកដែលអាចកំណត់អត្តសញ្ញាណបានពីទិន្នន័យនោះ។ ម៉្យាងវិញទៀត វាគឺជាព័ត៌មានច្បាស់លាស់អំពីបុគ្គលជាក់លាក់ និងអនុញ្ញាតឱ្យប្រើប្រាស់អត្តសញ្ញាណរបស់បុគ្គលនោះ។ ជាឧទាហរណ៍ ច្បាប់របស់សហរដ្ឋអាមេរិកកំណត់និយមន័យយ៉ាងទូលំទូលាយថា «ទិន្នន័យផ្ទាល់ខ្លួន» មានន័យថា «រាល់ព័ត៌មានទាំងឡាយដែលជាប់ទាក់ទង ឬអាចជាប់ទាក់ទងយ៉ាងត្រឹមត្រូវជាមួយនឹងបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណ ឬអាចកំណត់អត្តសញ្ញាណបាន»។[៤៣] ទិន្នន័យផ្ទាល់ខ្លួននឹងបង្ហាញនៅក្នុងអ្វីគ្រប់យ៉ាង ដែលអាចបញ្ជាក់ពីវត្តមានរាងកាយរបស់អ្នកនៅកន្លែងណាមួយ។ ដូច្នេះ រូបភាពកាមេរ៉ាឃ្លាំមើលរបស់អ្នកគឺជាទិន្នន័យផ្ទាល់ខ្លួន ក៏ដូចជាស្នាមម្រាមដៃដែរ។ នៅលើកំណត់សម្គាល់ ព័ត៌មានផ្ទាល់ខ្លួនគឺជាទិន្នន័យផ្ទាល់ខ្លួន ប៉ុន្តែមិនមែនទិន្នន័យផ្ទាល់ខ្លួនទាំងអស់គឺជាព័ត៌មានផ្ទាល់ខ្លួននោះទេ។

ទិន្នន័យផ្ទាល់ខ្លួនសំខាន់ផ្សេងៗ ស្ថិតនៅលើគោលគំនិតផ្លូវច្បាប់នៃទិន្នន័យផ្ទាល់ខ្លួនដែលមានលក្ខណៈរសើបជាសំណុំជាក់លាក់នៃ «ប្រភេទពិសេស» ដែលត្រូវចាត់ចែងដោយមានសុវត្ថិភាពបន្ថែម។ ប្រភេទទាំងនេះរួមមាន ពូជសាសន៍ ឬជាតិពិន្ទុ ទស្សនៈនយោបាយ ជំនឿសាសនា ឬ ទស្សនៈខាងជំនឿ សមាជិកភាពសហជីព ទិន្នន័យហ្សែន ទិន្នន័យជីវមាត្រ (កន្លែងដែលដំណើរការដើម្បីកំណត់អត្តសញ្ញាណពិសេសរបស់នរណាម្នាក់)។ ទិន្នន័យផ្ទាល់ខ្លួនរសើបនេះទាមទារឱ្យមានការការពារបន្ថែមតាមពីច្បាប់។

បន្ថែមលើប្រភេទទិន្នន័យផ្ទាល់ខ្លួនទាំងនេះ គឺទិន្នន័យមិនផ្ទាល់ខ្លួន។ ទិន្នន័យមិនផ្ទាល់ខ្លួន គឺជាសំណុំទិន្នន័យទាំងឡាយដែលមិនមានព័ត៌មានដែលអាចកំណត់អត្ត-សញ្ញាណផ្ទាល់ខ្លួនបាន។ ឧទាហរណ៍ ការបង្កើតគណនីគេហទំព័រសម្រាប់សេវាអតិថិជនដែលមានព័ត៌មានផ្ទាល់ខ្លួន (ឈ្មោះ អាយុ ភេទ និងព័ត៌មានទំនាក់ទំនងផ្សេងទៀតរបស់បុគ្គល) នឹងក្លាយជាទិន្នន័យមិនផ្ទាល់ខ្លួន ប្រសិនបើឈ្មោះ និងព័ត៌មានទំនាក់ទំនងត្រូវបានដកចេញ។ ថ្មីៗនេះ នៅក្នុងប្រទេសឥណ្ឌា គណៈកម្មាធិការរដ្ឋាភិបាលមួយបានធ្វើរបាយការណ៍មួយ ដែលបានបែងចែកទិន្នន័យមិនផ្ទាល់ខ្លួនជាបីប្រភេទសំខាន់ៗ៖ ទិន្នន័យសាធារណៈ ទិន្នន័យសហគមន៍ និងទិន្នន័យឯកជនមិនផ្ទាល់ខ្លួន។ ដូចបានពិពណ៌នា «ទិន្នន័យទាំងអស់ដែលរដ្ឋាភិបាល និងទីភ្នាក់ងាររបស់ខ្លួនបានប្រមូល ដូចជាទិន្នន័យជំរឿន ទិន្នន័យដែលប្រមូលដោយសាជីវកម្មក្រុង អំពីចំណូលអាករសរុបក្នុងគ្រាជាក់លាក់ណាមួយ ឬព័ត៌មានទាំងឡាយដែលប្រមូលបានក្នុងអំឡុងពេលអនុវត្តការងារទាំងឡាយក្រោមមូលនិធិសាធារណៈ ត្រូវបានរក្សាទុកក្រោមឆ័ត្រនៃទិន្នន័យសាធារណៈមិនមែនផ្ទាល់ខ្លួន»។[៤៤] ទិន្នន័យសហគមន៍មិនផ្ទាល់ខ្លួនត្រូវបានគេចាត់ទុកថាជា «ឧបករណ៍កំណត់អត្តសញ្ញាណទិន្នន័យអំពីក្រុមមនុស្ស

ដែលមានទីតាំងភូមិសាស្ត្រ សាសនា ការងារ ឬផលប្រយោជន៍សង្គមផ្សេងទៀត»។[៤៥] ហើយទិន្នន័យឯកជនមិនផ្ទាល់ខ្លួនគ្របដណ្តប់លើទិន្នន័យ «ដែលផលិតដោយបុគ្គល ដែលអាចទទួលបានពីកម្មវិធីមានកម្មសិទ្ធិ ឬចំណេះដឹងផ្សេងៗ»។

ទិន្នន័យខ្លះត្រូវបានការពារ ហើយខ្លះទៀតមិនត្រូវបានការពារ។ ការការពារទិន្នន័យត្រូវបានពិពណ៌នាថាជា «ច្បាប់ដែលត្រូវបានបង្កើតឡើងដើម្បីការពារទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។ នៅក្នុងសង្គមសម័យទំនើប ដើម្បីផ្តល់សិទ្ធិដល់យើងក្នុងការគ្រប់គ្រងទិន្នន័យរបស់យើង និងដើម្បីការពារយើងពីការរំលោភបំពាន ច្បាប់ការពារទិន្នន័យចាំបាច់ត្រូវរារាំង និងកំណត់ទ្រង់ទ្រាយនៃសកម្មភាពរបស់ក្រុមហ៊ុន និងរដ្ឋាភិបាល»។[៤៦]

ការបំពានទិន្នន័យផ្ទាល់ខ្លួនមានន័យថា «ការរំលោភលើសុវត្ថិភាពដែលជាយថាហេតុនាំទៅដល់ការបំផ្លិចបំផ្លាញខុសច្បាប់ ការបាត់បង់ ការកែប្រែ ការបញ្ចេញព័ត៌មានដោយគ្មានការអនុញ្ញាត ឬការលួចប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនដែលត្រូវបានបញ្ជូន រក្សាទុក ឬដំណើរការផ្សេងទៀត» (មាត្រា ៤ កថាខណ្ឌ ១២ នៃបទប្បញ្ញត្តិការពារទិន្នន័យទូទៅ)។

ប្រភេទទិន្នន័យដែលប្រមូលបានតាមរយៈនីតិវិធីចុះបញ្ជីដីរបស់ជនជាតិដើមភាគតិច គឺជាព័ត៌មានមូលដ្ឋាន ព្រោះការការពារនឹងមានការប្រែប្រួលពីប្រភេទទិន្នន័យមួយទៅប្រភេទមួយទៀត។ ឧទាហរណ៍នៃបទប្បញ្ញត្តិរបស់កម្ពុជាស្តីពីការពារទិន្នន័យ គឺជាប្រធានបទដ៏ល្អមួយ ក្នុងន័យថាមិនមានយន្តការច្បាប់ជាក់លាក់បែបនេះទេនាពេលបច្ចុប្បន្ន។ ល្អបំផុត យើងអាចសង្កេតមើលធាតុផ្សំមួយចំនួននៅក្នុងច្បាប់ថ្មីស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប៉ុន្តែវាទាក់ទងតែទិន្នន័យនិម្មិតនៅក្នុងគម្រោងអ្នកប្រើប្រាស់/អ្នកផ្តល់សេវាប៉ុណ្ណោះ។ ចន្លោះប្រហោងនៃច្បាប់នេះនឹងត្រូវបានវិភាគនៅក្នុងផ្នែកចុងក្រោយនៃឯកសារនេះ។

ជាមួយនឹងវឌ្ឍនភាពជាយថាហេតុនៃបទប្បញ្ញត្តិស្តីពីការពារទិន្នន័យទូទៅ និងឯកសារនានា យើងធ្វើការឆ្លុះបញ្ចាំងជាក់លាក់បន្ថែម ទៅលើអធិបតេយ្យភាពនៃទិន្នន័យជនជាតិដើមភាគតិច។ ឧទាហរណ៍ផ្នែកច្បាប់មួយចំនួនអាចផ្តល់ការបកស្រាយយ៉ាងទូលំទូលាយអំពីបញ្ហាជុំវិញការការពារទិន្នន័យក៏ដូចជាករណីជនជាតិដើមភាគតិចផងដែរ។

# ខ. ករណីជាក់លាក់នៃការប្រមូលទិន្នន័យជនជាតិដើមភាគតិច

នៅក្នុងជំពូកនេះ យើងពិនិត្យមើលកាន់តែស៊ីជម្រៅនូវគោលការណ៍ឃែរ CARE និងហ្វ៊ែរ FAIR នៅពេលដែលត្រូវបានអនុវត្តចំពោះអភិបាលកិច្ចទិន្នន័យជនជាតិដើមភាគតិច។ ទិន្នន័យបានក្លាយជាផ្នែកសារវន្តមួយដែល «ផ្តល់លទ្ធភាពដល់ជនជាតិដើមភាគតិចក្នុងការអនុវត្តសិទ្ធិបុគ្គល និងសិទ្ធិសមូហភាពរបស់ពួកគេក្នុងការសម្រេចចិត្តដោយខ្លួនឯង»[៤៧] ខណៈដែលយើងមើលឃើញពីការវិវដ្តនៃគោលលទ្ធិអធិបតេយ្យភាពនៃទិន្នន័យជនជាតិដើមភាគតិច។ ដូចដែលសារព័ត៌មានសាកលវិទ្យាល័យជាតិអូស្ត្រាលីបានថ្លែងបន្ទាប់ពីសិក្ខាសាលាស្តីពី «អធិបតេយ្យភាពនៃទិន្នន័យសម្រាប់ជនជាតិ ដើមភាគតិច៖ ការអនុវត្តបច្ចុប្បន្ន និងតម្រូវការនាពេលអនាគត» នៅក្នុងខែកក្កដា ឆ្នាំ២០១៥ «លក្ខណៈចម្រុះនៃអធិបតេយ្យភាពទិន្នន័យជនជាតិដើមភាគតិច នាំមកនូវបញ្ហាផ្សេងៗ ជាច្រើន រាប់ចាប់ពីផ្នែកច្បាប់ និងក្រមសីលធម៌ជុំវិញការផ្ទុកទិន្នន័យ ភាពជាម្ចាស់កម្មសិទ្ធិ ការប្រើប្រាស់ និងការយល់ព្រម សិទ្ធិកម្មសិទ្ធិបញ្ញា និងការពិចារណាជាក់ស្តែងលើរបៀបប្រើប្រាស់ទិន្នន័យក្នុង បរិបទនៃការស្រាវជ្រាវ គោលនយោបាយ និងការអនុវត្ត ជាក់ស្តែង»។[៤៨] គោលគំនិតអំពីអធិបតេយ្យភាពរបស់ជនជាតិដើមភាគតិចលើទិន្នន័យរបស់ពួកគេ មានន័យថាជាការបង្កើតវិថីជានិរន្តរ៍មួយដើម្បីពង្រឹង «សិទ្ធិចូលរួមក្នុងការសម្រេចចិត្តស្របតាមគុណតម្លៃជនជាតិដើមភាគតិច និងផលប្រយោជន៍រួម»។[៤៩]

បន្ទាប់ពីការស្រាវជ្រាវតាមការណែនាំរបស់ GIDA យើងទទួលស្គាល់ថា «ទិន្នន័យជនជាតិដើមភាគតិច ដែលក្នុងនោះរួមមានទិន្នន័យដែលប្រមូល

ដោយរដ្ឋាភិបាល និងស្ថាប័នអំពីជនជាតិដើមភាគតិច និងទឹកដីរបស់ពួកគេ គឺអាស្រ័យលើសមត្ថភាព និងលទ្ធភាពផ្ទាល់របស់ជនជាតិដើមភាគតិចក្នុងការយល់ដឹងអំពីសិទ្ធិមនុស្ស និងការទទួលខុសត្រូវរបស់ពួកគេចំពោះការបង្កើតអ្វីគ្រប់យ៉ាង»។[៥០]

ការប្រមូលទិន្នន័យនេះគឺជាអាវុធមុខពីរ[៥១] ក្នុងបុព្វហេតុរបស់ជនជាតិដើមភាគតិច ដោយវាគឺជាជំនួយដ៏មានសក្កា-នុពលសម្រាប់ជនជាតិដើមភាគតិចផង និងជាការគំរាម-កំហែងផង ប្រសិនបើទិន្នន័យត្រូវបានដំណើរការប្រឆាំងនឹងពួកគេ ដើម្បីជាប្រយោជន៍រួមរបស់ប្រទេសជាតិ។ ក្នុងការបង្កើតទិន្នន័យសម្រាប់ប្រើប្រាស់ កម្រងគោលការណ៍ចម្បងជុំវិញការអនុវត្តល្អៗ លើទិន្នន័យ គឺគោលការណ៍ហ្វែរ[៥២] (ពោលគឺ អាចរកបាន អាចប្រើប្រាស់បាន អាចធ្វើអន្តរកម្មបាន អាចប្រើឡើងវិញបាន)» ដែលលើកទឹកចិត្តឱ្យមានចលនាទិន្នន័យបើកទូលាយ និងចលនាផ្សេងៗ ដើម្បីពិចារណាទាំងលើមនុស្ស និងគោលបំណងក្នុងការតស៊ូមតិនិងការសម្រេចតាមគោលបំណង»។[៥៣] គោលការណ៍ហ្វែរប្រើវិធីសាស្ត្រផ្តោតលើទិន្នន័យសម្រាប់ចាត់ចែង និងគ្រប់គ្រងទិន្នន័យតាមបែបវិទ្យាសាស្ត្រ ហើយជាក្របខណ្ឌទូទៅមួយនៃការប្រើប្រាស់ទិន្នន័យ។ កម្រងគោលការណ៍ទីពីរដែលមានប្រយោជន៍ គឺឃែរ (ផលប្រយោជន៍រួម សិទ្ធិអំណាចក្នុងការគ្រប់គ្រង ការទទួលខុសត្រូវ ក្រមសីលធម៌)។ គោលគំនិតទាំងនេះត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងករណីជនជាតិដើមភាគតិចជាក់លាក់។ គោលការណ៍ ឃែរ គាំទ្រដល់អភិបាលកិច្ចទិន្នន័យជនជាតិដើមភាគតិច «ឆ្លុះបញ្ចាំងពីតួនាទីដ៏សំខាន់នៃទិន្នន័យក្នុងការជំរុញដល់ការបង្កើតថ្មីរបស់ជនជាតិដើមភាគតិច និងការសម្រេចចិត្តដោយខ្លួនឯង»។[៥៤]

គោលការណ៍រួមទាំងអស់នេះ មានគោលបំណងរក្សាផលប្រយោជន៍របស់ជនជាតិដើមភាគតិចនៅក្នុងការតស៊ូរបស់ជនជាតិភាគតិចដែលជាញឹកញាប់ មិនមានតុល្យភាព ដើម្បីឱ្យគេទទួលស្គាល់សិទ្ធិរបស់ខ្លួន។ GIDA បញ្ជាក់ជាចុងក្រោយថា «ការកើនឡើងនៃបណ្តាញអធិបតេយ្យភាពទិន្នន័យជាតិជនជាតិដើមភាគតិច ឆ្លុះបញ្ចាំងពីការព្រួយបារម្ភជាសកលកាន់តែខ្លាំងឡើងៗ អំពីតម្រូវការក្នុងការការពារប្រឆាំងនឹងការប្រើប្រាស់មិនសមស្របនូវទិន្នន័យជនជាតិដើមភាគតិច និង ធានាថាជនជាតិដើមភាគតិចគឺជាអ្នកទទួលផលចម្បងនៃទិន្នន័យរបស់ពួកគេ»។[៥៥] ជាឧទាហរណ៍នៅអាមេរិក គឺបណ្តាញអធិបតេយ្យភាពទិន្នន័យជនជាតិដើមសហរដ្ឋអាមេរិក (USIDSN) ដែលធ្វើការលើការស្រាវជ្រាវទិន្នន័យ ការតស៊ូមតិគោលនយោបាយ និងការអប់រំ។ ជាឧទាហរណ៍នៅប្រទេសនូវែលសេឡង់គឺបណ្តាញអធិបតេយ្យភាពទិន្នន័យ Maori ដែលបានដំណើរការតាំងពីឆ្នាំ ២០១៥។ ការអភិវឌ្ឍរបស់អូស្ត្រាលីរួមមាន Maiam Nayri Wingara Aboriginal និង Torres Strait Islander Data Strait Collective ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៧។

គំនិតផ្តួចផ្តើមទាំងនេះ មិនទាន់មានក្នុងចំណោមជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជានៅឡើយទេ ទោះបីជាអង្គការមិនមែនរដ្ឋាភិបាលជាច្រើនកំពុងធ្វើការនិងសហការជាមួយជនជាតិដើមភាគតិច រួមទាំងតាមរយៈការលើកកម្ពស់ការយល់ដឹងអំពីទិន្នន័យ និងជំនួយផ្នែករដ្ឋបាលដើម្បីទទួលបានបណ្ណកម្មសិទ្ធិដីធ្លីក៏ដោយ។«សារៈសំខាន់នៃទិន្នន័យដើម្បីជំរុញវឌ្ឍនភាពនៃការសម្រេចចិត្តដោយខ្លួនឯង និងការអភិវឌ្ឍជនជាតិដើមភាគតិច ត្រូវបានយកចិត្តទុកដាក់ពីអង្គការមិនមែនរដ្ឋាភិបាលជនជាតិដើមភាគតិច (Tebtebba Foundation ២០០៨) សហគមន៍ និងកុលសម្ព័ន្ធ»[៥៦] ដែលបង្ហាញពីតួនាទីជាសារវន្តនៃការប្រមូលទិន្នន័យក្នុងការតស៊ូរបស់ជនជាតិដើមភាគតិច។ ទោះជាយ៉ាងណា ការងាររបស់អង្គការមិនមែនរដ្ឋាភិបាលលើការប្រមូលទិន្នន័យនៅក្នុងប្រទេសកម្ពុជាហាក់បីដូចជាមានប្រតិកម្មប្រឆាំងនឹងជនជាតិដើមភាគតិច ដោយសារវាផ្តល់ព័ត៌មានសំខាន់ៗ ដល់វិនិយោគិនអំពីកន្លែងដែលពួកគេអាចទទួលបានកម្មសិទ្ធិ នៅក្នុងតំបន់ព្រៃឈើដោយមិនបង្កើតការការពារច្រើនបន្ថែមទៀតដល់ជនជាតិដើមភាគតិច។ ផ្ទុយទៅវិញ ការវិវឌ្ឍនៃ «ចលនាបច្ចុប្បន្នឆ្ពោះទៅសម្រេចបានទិន្នន័យបើកទូលាយ និងវិទ្យាសាស្ត្របើកទូលាយ» (តំណាងដោយគោលការណ៍ហ្វែរ) ដោយសារវា «មិនបានចូលរួមចំណែកពេញលេញដល់សិទ្ធិ និងផលប្រយោជន៍របស់ជនជាតិដើមភាគតិច»។[៥៧] នេះមានន័យថា ការចុះបំពេញការងារដែលដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាលអាចនាំមកនូវផលអវិជ្ជ-

មាន។ «ជាលទ្ធផល ការប្រមូលទិន្នន័យជនជាតិដើមភាគតិចត្រូវបានចាត់ទុកថាជាការផ្តល់សេវាតាមតម្រូវការចម្បងរបស់រដ្ឋាភិបាល ជាជាងគាំទ្រដល់របៀបវារៈនៃការអភិវឌ្ឍជនជាតិដើមភាគតិច»។[៥៨] ដោយឡែក «ទោះបីជាយើងមិនអាចប្រកែកបាននូវតួនាទីសំខាន់មួយចំនួននៃការប្រមូលទិន្នន័យក៏ដោយ អ្វីដែលជនជាតិដើមភាគតិចកំពុងស្វែងរកគឺសិទ្ធិក្នុងការកំណត់អត្តសញ្ញាណ និងចូលរួមប្រកបដោយអត្ថន័យក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ការប្រមូល ផ្សព្វផ្សាយ និងគ្រប់គ្រងទិន្នន័យទាំងអស់អំពីពួកគេដែលត្រូវបានប្រមូល»។[៥៩] នេះមានន័យថាទាំងផលប្រយោជន៍របស់រដ្ឋ និងជនជាតិដើមភាគតិចត្រូវតែយកមកពិចារណា ដរាបណាមានការការពារតិចតួចបំផុតជុំវិញជនជាតិដើមភាគតិច។ ដូច្នេះហើយ សំខាន់បំផុត គឺត្រូវកសាងប្រព័ន្ធមួយដែលមាននិរន្តរភាព ដើម្បីការពារជនជាតិដើមភាគតិចទាំងនេះ និងបង្កើតគំនិតអំពីការប្រើប្រាស់ទិន្នន័យជនជាតិដើមភាគតិចតាមរបៀបមួយដែលរក្សាបាននូវអធិបតេយ្យភាព និងជីវភាពរស់នៅរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។

ជនជាតិដើមភាគតិចប្រឈមមុខនឹងហានិភ័យយ៉ាងធ្ងន់ធ្ងរក្នុងដំណើរឆ្ពោះទៅរកការទទួលស្គាល់សិទ្ធិ ដូចបានបង្ហាញក្នុងដំណើរការរៀបចំ និងចរចាសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP)។ តាមរយៈនេះ គេបានរកឃើញ «បញ្ហាភ្លោះពោលគឺកង្វះទិន្នន័យ និងព័ត៌មានជនជាតិដើមភាគតិចដែលអាចជឿជាក់បាន ព្រមទាំងការលួចចម្លង និងប្រើប្រាស់មិនសមស្របនូវចំណេះដឹងបែបប្រពៃណី និងបេតិកភណ្ឌវប្បធម៌របស់ពួកគេ»[៦០] ដែលជាបញ្ហាជាប់ជាប្រចាំ។ ជាក់ស្តែងណាស់ មានហានិភ័យនៃភាពលំអៀងនៅក្នុងដំណើរការប្រមូលទិន្នន័យ។ កង្វះការត្រួតពិនិត្យទិន្នន័យជនជាតិដើមភាគតិចពីសំណាក់ជនជាតិដើមភាគតិចអាចនាំឱ្យមានការផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យទាំងនោះ ដែលគំរាមកំហែងដល់ជីវភាពរស់នៅ និងទឹកដីរបស់ពួកគេ។

# ២. ការគំរាមកំហែងជាច្រើនពីការប្រមូលទិន្នន័យ និងការប៉ះពាល់ចំពោះជនជាតិដើមភាគតិច

ដោយបច្ចុប្បន្នមូលដ្ឋានទ្រឹស្តីត្រូវបានបង្កើតឡើងជុំវិញគោលគំនិតសំខាន់ៗ អំពីទិន្នន័យ និងការប្រមូលទិន្ន-ន័យដោយពិចារណាទៅលើស្ថានភាពជាក់ស្តែងរបស់ជនជាតិដើមភាគតិច ដូច្នេះហើយវាមានសារៈសំខាន់ណាស់ ដែលត្រូវយល់ដឹងអំពីការគំរាមកំហែងចម្បងៗចំពោះការប្រើប្រាស់ទិន្នន័យរបស់ពួកគេ។ មានបញ្ហាចម្បងពីរបានកើតឡើង។ កង្វល់ចម្បងមួយគឺនៅតែស្ថិតនៅជុំវិញការគំរាមកំហែងចំពោះឯកជនភាពរបស់ជនជាតិដើមភាគតិចតាមរយៈដំណើរការនីតិវិធីនៃការចុះបញ្ជីដីធ្លី។ ទីពីរ សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការគាំទ្រ ទំនងជាមានប្រតិកម្មប្រឆាំងនឹងជនជាតិដើមភាគតិច ប្រសិនបើអ្វីដែលបានផលិតឡើងមានភាពលំអៀង មិនពេញលេញ ឬជាទិន្នន័យដែលមិនតំណាងត្រឹមត្រូវ។

## ក. សកម្មភាពមនុស្សធម៌របស់អង្គការមិនមែនរដ្ឋាភិបាលទាំងជួយ និងបង្កគ្រោះថ្នាក់ដល់ស្ថានភាពរបស់ជនជាតិដើមភាគតិច

វិធីសាស្រ្តប្រមូលទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាលបានវិវត្តជាទៀងទាត់ព្រោះថាអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយដែលជំរឿនគឺជា «បទដ្ឋានមាស» ក្នុងការប៉ាន់ប្រមាណ និង ព្យាករណ៍ចំនួនប្រជាជនជាពិសេសលើក្រុមប្រជាជន និងតំបន់ភូមិសាស្រ្តតូចៗដែលសុទ្ធតែមានជនជាតិដើមភាគតិច។[៦១] គេបន្តធ្វើបែបនេះរហូតទាល់តែមានការផ្លាស់ប្តូរទៅរកជំរឿន 'ចុះដើរប្រ-មូលទិន្នន័យ' បែបប្រពៃណី និងបន្តប្រើប្រាស់ «ការស្ទង់មតិរឹលជុំ ការចុះបញ្ជីប្រជាជន និងទិន្នន័យរដ្ឋបាល រួមជាមួយនឹងការប្រើប្រាស់កាន់តែច្រើននូវបច្ចេកវិទ្យាឌីជី-ថល»។ ទោះជាយ៉ាងណា ការផ្លាស់ប្តូរនេះអាចត្រូវបានគេយល់ថាជាការប៉ះពាល់យ៉ាងខ្លាំងទាំងលើគុណភាព និងការបែងចែកទិន្នន័យជនជាតិដើម ដូចដែលយើងអាចឃើញស្រាប់តាមរយៈឧទាហរណ៍នៃប្រទេសកាណាដា[៦២] នៅដើមឆ្នាំ២០១០។ ឧទាហរណ៍មួយទៀតគឺការអនុវត្តហេដ្ឋារចនាសម្ព័ន្ធទិន្នន័យបែបសមាហរណកម្ម និងជំរឿនរដ្ឋបាលពេញលេញរបស់ប្រទេស Aotearoa ឬហៅថាប្រទេសនូវែលសេឡង់[៦៣] បានបង្ហាញបញ្ហានៃភាពអនាមិកនៃទិន្នន័យជនជាតិដើមភាគតិច ដែលនាំទៅដល់ការអន្ត-រាគមន៍ចំគោលដៅ។អ្នកនិពន្ធលើកឡើងថាការផ្លាស់ប្តូរការដំណើរការទិន្នន័យបែបនេះអាចមាន «ការប៉ះពាល់យ៉ាងខ្លាំងចំពោះការគ្រប់គ្រងគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃទិន្នន័យជនជាតិដើមភាគតិច»។ ជាក់ស្តែង មានការព្រួយបារម្ភអំពីយុទ្ធសាស្រ្តក្នុងការបន្តអភិវឌ្ឍគោលការណ៍អធិបតេយ្យភាពទិន្នន័យជនជាតិដើមភាគតិច ដោយសារវិធីសាស្រ្តប្រមូលទិន្នន័យអាចបង្កជាគ្រោះថ្នាក់ខ្លាំងចំពោះជនជាតិដើមភាគតិច។

នេះគឺជាឧទាហរណ៍ខ្លះៗ នៃការប្រមូលទិន្ន-ន័យរបស់អង្គការមិនមែនរដ្ឋាភិបាលដែលប្រមូលព័ត៌មានដើម្បីជួយសហគមន៍ក្នុងប្រទេសកម្ពុជា ប៉ុន្តែទន្ទឹមនឹងនោះដែរ អនុញ្ញាតឱ្យមានការប្រើប្រាស់ព័ត៌មាន និងគំរាមកំហែងដល់អធិបតេយ្យភាព ទឹកដី និងជីវភាពរស់នៅរបស់ជន-ជាតិដើមភាគតិច។

ឧទាហរណ៍ទីមួយ គឺរបាយការណ៍ស្តីពី «សិទ្ធិទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិចនៅកម្ពុជា» ផលិតដោយមជ្ឈមណ្ឌល ម.ស.ម.ក ដែលនឹងជួយផ្តល់នូវទិដ្ឋភាពទូទៅនៃគម្រោងកំណែទម្រង់

ដីធ្លីនេះ «គូសបញ្ជាក់ពីឧបសគ្គចំពោះការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ដោយផ្អែកលើទិន្នន័យដែលគម្រោងប្រមូលបាន»។ ជារួម ម.ស.ម.ក និងរដ្ឋាភិបាលបាននិងកំពុងបញ្ចេញ និងវិភាគទិន្នន័យជនជាតិដើមភាគតិចដែលប្រមូលបានក្នុងអំឡុងពេលឈ្លបយកការណ៍ពីសំណាក់រដ្ឋាភិបាល និងចុះអនុវត្តការងារក្នុងដំណើរការនីតិវិធីចុះបញ្ជីដីធ្លី។ ទោះបីជា «គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីបង្ហាញទិន្នន័យដែលប្រមូលបានពីការស្រាវជ្រាវរបស់គម្រោង ស្តីពីឧបសគ្គដែលសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាជួបប្រទះនៅពេលទាមទារសិទ្ធិកម្មសិទ្ធិដីធ្លីតាមរយៈការស្នើសុំបណ្ណកម្មសិទ្ធិសមូហភាព»[៦៤] ក៏ដោយ ក៏ការបញ្ចេញព័ត៌មាន និងវិភាគបន្ថែមលើលទ្ធផលនៃរបាយការណ៍នេះ អាចត្រូវបានគេមើលឃើញថាជាការគំរាមកំហែងដល់ជនជាតិដើមភាគតិច ដោយសារទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានប្រើប្រាស់។ ការរក្សាឱ្យមានតុល្យភាពរវាងជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល និងឧត្តមប្រយោជន៍របស់ជនជាតិដើមភាគតិចបានក្លាយជាបញ្ហាជាក់ស្តែងមួយ។

ការប្រមូលទិន្នន័យទីពីរដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយ «ពិនិត្យមើលផលប៉ះពាល់នៃការរំលោភដីធ្លីមកលើជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាដែលអូសបន្លាយពេលជាច្រើនឆ្នាំ»។[៦៥] នេះបង្ហាញពីភស្តុតាងនៃការទន្ទ្រានយកដីតាមរយៈសម្បទានដីសេដ្ឋកិច្ចដែលរដ្ឋបានផ្តល់ដល់គម្រោងកសិឧស្សាហកម្ម គម្រោងរុករករ៉ែ និងទេសចរណ៍ ព្រមទាំងការព្រួយបារម្ភអំពីផលប៉ះពាល់របស់វាមកលើជនជាតិដើមភាគតិច។ ជាទូទៅ វិធីសាស្ត្រនៃការប្រមូលទិន្នន័យដែលបានប្រើប្រាស់នៅទីនេះ គឺផ្អែកលើការស្ទង់មតិ និងការសម្ភាសន៍ជនជាតិដើមភាគតិចដែលរស់នៅក្នុងឃុំស្រែព្រះ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។[៦៦] ទាំងនេះបានផ្តល់លទ្ធផលទាំងបរិមាណ និងគុណភាព ដែលអនុញ្ញាតឱ្យគូសផែនទីតំបន់យ៉ាងច្បាស់លើក្រដាស។ ការប្រមូលទិន្នន័យរួមមានទិន្នន័យអំពីភេទ និងប្រភេទទ្រព្យសម្បត្តិគ្រួសារ។[៦៧]

តំណាងជនជាតិដើមភាគតិចមួយចំនួនបានក្រើនរំលឹកអំពី «ទំនាក់ទំនងនៃក្របខណ្ឌស្ថិតិដែលមានស្រាប់ក្នុងការឆ្លុះបញ្ចាំងពីទស្សនៈសកលរបស់ខ្លួន និងបានលើកឡើងថាពួកគេមិនបានចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ និងអភិបាលកិច្ច»។ ជាក់ស្តែងណាស់ មានហានិភ័យនៃភាពលំអៀង ហើយភាគច្រើនធ្វើឱ្យប៉ះពាល់ដល់ជំហររបស់ជនជាតិដើមភាគតិច ក៏ដូចជាភាពមិនច្បាស់លាស់នៃស្ថានភាពចម្រុះជាក់ស្តែងរបស់ពួកគេ។

ទោះបីជាមានគ្រោះថ្នាក់ក៏ដោយ ក៏មានដំណោះស្រាយមួយចំនួនត្រូវបានបង្កើតឡើង សម្រាប់ជាជំនួយក្នុងបុព្វហេតុជនជាតិដើមភាគតិច។ សំណើទីមួយ គឺការបញ្ឈប់ការត្រួតត្រាលើអធិបតេយ្យភាពទិន្នន័យជនជាតិដើមភាគតិច។[៦៨] អ្នកជំនាញបានលើកឡើងនូវ «អនុសាសន៍អំពីវិធី សាស្ត្រនៃការប្រមូលទិន្នន័យនិងលទ្ធភាពនៃការបញ្ឈប់ការត្រួតត្រាលើទិន្នន័យជនជាតិដើមភាគតិច ក៏ដូចជាវិធីសាស្ត្រ និងសូចនាករដែលត្រូវប្រើដើម្បីវាស់វែងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ហើយបច្ចុប្បន្នគឺគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលទើបតែត្រូវបានអនុម័តថ្មីៗ»។[៦៩] បញ្ហាទិន្នន័យមានទំនាក់ទំនងជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១៧ ។ទន្ទឹមនឹងនេះដែរ តាមការជាក់ស្តែង គឺចាំបាច់ត្រូវមានទិន្នន័យបន្ថែមទៀត ដើម្បីអាចតាមដានវឌ្ឍនភាពក្នុងចំណោមជនជាតិដើមភាគតិច និងក្រុមជនជាតិដើមភាគតិច។[៧០] ដូចបានបញ្ជាក់នៅ ក្នុងរបាយការណ៍មួយរបស់ក្រុមប្រឹក្សាអ្នកជំនាញឯករាជ្យនៃអគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីបដិវត្តន៍ទិន្នន័យសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព៖ «ទិន្នន័យគឺជាសរសៃឈាមនៃការសម្រេចចិត្ត និងជាវត្ថុធាតុដើមនៃគណនេយ្យភាព។ បើគ្មានទិន្នន័យដែលមានគុណភាពខ្ពស់ និងផ្តល់ព័ត៌មានត្រឹមត្រូវតាមនិន្នាការត្រឹមត្រូវ នៅពេលវេលាត្រឹមត្រូវ នោះការរៀបចំការតាមដាន និងវាយតម្លៃលើប្រសិទ្ធភាពគោលនយោបាយ គឺស្ទើរតែមិនអាចធ្វើទៅរួចទេ»។[៧១] នេះគូសបញ្ជាក់ពីគោលបំណងជាសារវន្ត និងបញ្ហាចម្បងនៃការប្រមូល និងប្រើប្រាស់ទិន្នន័យ។

ក្រុមអ្នកស្រាវជ្រាវដដែលបញ្ជាក់ថា «មានការលំបាកមួយចំនួនក្នុងការវាស់វែងសមិទ្ធផលសិទ្ធិមនុស្សទាក់ទងនឹងទិន្នន័យបរិមាណ ឬស្ថិតិ ដោយសារការវាយតម្លៃលើការអនុវត្តសិទ្ធិមនុស្ស ជានិច្ចកាលមានធាតុផ្សំដ៏មានគុណភាពយ៉ាងរឹងមាំ។ ទោះជាយ៉ាងណា ផ្អែក

តាមបទពិសោធន៍ក្នុងការបង្កើតសូចនាករ ដើម្បីវាស់វែងវឌ្ឍនភាពក្នុងការអនុវត្តសិទ្ធិមនុស្សក្នុងបរិបទផ្សេងទៀត បានបង្ហាញថា ការប្រមូលទិន្នន័យដែលមានប្រយោជន៍ជាស្ថិតិអាចធ្វើទៅបានអនុលោមតាមច្បាប់សិទ្ធិមនុស្ស»។[៧២] នេះបង្ហាញថាគោលដៅជាសារវន្តមួយនៃការប្រើប្រាស់ទិន្នន័យក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺដើម្បីផ្សារភ្ជាប់វឌ្ឍនភាព និងតាមដានការវិវត្តនៃសិទ្ធិមនុស្ស។ ដើម្បីឆ្លើយតបនឹងភាពមិនពេញលេញនៃទិន្នន័យ និងកង្វះតំណាងទិន្នន័យត្រឹមត្រូវដែលប្រមូលបាន «ទិន្នន័យគួរត្រូវបានបង្កើតឡើងដោយវាស់វែងពីការបំពេញនូវសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការទទួលបានដីធ្លី និងកម្មសិទ្ធិដីធ្លី ទឹកដី និងធនធាន អំពីវឌ្ឍនភាពនៃការចូលរួមរបស់ពួកគេក្នុងការសម្រេចចិត្ត និងការគ្រប់គ្រងលើដំណើរការអភិវឌ្ឍរបស់ពួកគេផ្ទាល់ អំពីអ្វីដែលគ្រប់គ្រងលើទិន្នន័យ និងចំណេះដឹងដែលពួកគេមាន អំពីការរើសអើង និងការផាត់ចេញពីសកម្មភាពដែលពួកគេជួបប្រទះទាក់ទងនឹងសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់ពួកគេ»។[៧៣] គោលដៅគឺដើម្បីបញ្ឈប់ការត្រួតត្រាលើអធិបតេយ្យភាពជនជាតិដើមភាគតិច។ វិធីសាស្ត្រប្រមូលទិន្នន័យត្រូវអនុវត្តតាមគោលការណ៍ដែលក្នុងនោះជនជាតិដើមភាគតិចគួរតែសម្រេចចិត្តថា តើត្រូវធ្វើអ្វីជាមួយទិន្នន័យទាំងនេះដោយខ្លួនឯង។[៧៤] សមិទ្ធផលការងាររបស់សាស្ត្រាចារ្យ Chidi Oguamanam បង្ហាញថា អធិបតេយ្យភាពទិន្នន័យជនជាតិដើមភាគតិច គឺជា «ឧបករណ៍ដ៏សំខាន់ក្នុងការជំរុញចក្ខុវិស័យរបស់ជនជាតិដើមភាគតិចក្នុងការសម្រេចដោយខ្លួនឯងលើការអភិវឌ្ឍ ដែលជាផ្នែកមួយនៃតក្កវិជ្ជានៃការសម្រេចចិត្តទូលំទូលាយដោយខ្លួនឯង»។[៧៥] ការធ្វើបែបនេះស្របគ្នាជាមួយនឹងវិសាលភាពនៃតួអង្គរបស់អង្គការសហប្រជាជាតិ ដូចជាធនាគារពិភពលោក និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដោយចាត់ទុកអធិបតេយ្យភាពទិន្នន័យជនជាតិដើមភាគតិចជាឧបករណ៍សម្រាប់ «ការអភិវឌ្ឍ» ព្រោះទិន្នន័យបច្ចុប្បន្នមានតម្លៃសេដ្ឋកិច្ចយ៉ាងជ្រាលជ្រៅ ហើយគួរតែជួយជំរុញកំណើនប្រកបដោយនិរន្តរភាព។ ក្នុងន័យនេះ ចាំបាច់ត្រូវយល់ដឹងថា ជនជាតិដើមភាគតិចកំពុងធ្វើការតវ៉ាយ៉ាងខ្លាំងចំពោះទង្វើនៃការប្រើប្រាស់ទិន្នន័យដែលធ្វើឡើងប្រឆាំងនឹងការទាមទាររបស់ពួកគេឱ្យមានអធិបតេយ្យភាព និងការសម្រេចចិត្តដោយខ្លួនឯង។ ការអះអាងនេះមានភាពស៊ីសង្វាក់គ្នាទាំងស្រុងជាមួយនឹងទស្សនៈនៃគោលការណ៍ឃែរ។ ជាចុងក្រោយ ការជជែកដេញដោលបាននាំទៅរកសន្ទស្សន៍អភិវឌ្ឍន៍ជនជាតិដើមភាគតិចដោយនិរន្តរភាពដាច់ដោយឡែកមួយ ដែលដើរទន្ទឹមគ្នាជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ វិធីសាស្ត្រនេះគឺស្របតាមតម្រូវការខ្លាំងឡើងៗនូវវេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច (UNPFII ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០០) ដើម្បីបង្កើនការផ្តោតយកចិត្តទុកដាក់របស់ខ្លួនលើរបៀបវារៈនៃការអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងស្នើឱ្យមានអភិក្រមគោលនយោបាយជាក់លាក់ និងមានវឌ្ឍនភាពបន្ថែមទៀត។

ប្រសិនបើគោលដៅរបស់អង្គការមិនមែនរដ្ឋាភិបាល គឺដើម្បីជួយ និងនិយាយប្រឆាំងនឹងការរំលោភយកដីធ្លី នោះការប្រមូលទិន្នន័យអាចបង្កគ្រោះថ្នាក់ចំពោះជនជាតិដើមភាគតិច ដោយសារវាប៉ះពាល់ជាសាធារណៈដល់ការតស៊ូផ្នែកហិរញ្ញវត្ថុរបស់ពួកគេ ឬផ្តល់នូវតំណាងត្រឹមត្រូវ[៧៦] នៃវត្តមានរបស់ពួកគេនៅក្នុងតំបន់។ ការប្រយុទ្ធតស៊ូរបស់អង្គការមិនមែនរដ្ឋាភិបាលមានផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានលើសហគមន៍ទាំងនេះ និងបាត់បង់ការគ្រប់គ្រងរបស់ជនជាតិដើមភាគតិចលើទិន្នន័យជនជាតិដើមភាគតិច។

## ខ. ការចុះប្រមូលទិន្នន័យដោយរដ្ឋបាលសុរិយោដីក្នុងវិសាលភាពនៃការចុះបញ្ជីដីធ្លី

យន្តការរដ្ឋបាលនៃការចុះបញ្ជីដីធ្លីនេះបានចាប់ផ្តើមនៅឆ្នាំ១៩៨៩។ ការចុះបញ្ជីដីធ្លីបច្ចុប្បន្នសម្រេចបានរហូតដល់ចំនួន ៤.៩៧៦.០៩៥ បណ្ណ ដែលក្នុងនោះ ៤.៧៧៧.៧៧១ បណ្ណត្រូវបានចេញជូនម្ចាស់ដី។[៧៧] ៦៨,២៥% នៃក្បាលដីប្រមាណ ៧ លានមានសិទ្ធិចុះបញ្ជីគិតត្រឹមខែមិថុនា ឆ្នាំ២០១៨។[៧៨] ទោះជាយ៉ាងណា ប្រជាជនមួយចំនួនធំនៅតែមិនបានដឹងអំពីឧបករណ៍សុរិយោដីនេះ។[៧៩] ច្បាប់បានឆ្លងកាត់ការធ្វើបច្ចុប្បន្នភាពជាច្រើន

លើកជាទៀងទាត់។ សរុបមក «គោលគំនិតនៃសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងចាត់ចែងដីធ្លីដែលបន្សល់ទុកពីដូនតារបស់ពួកគេត្រូវបានផ្លាស់ប្តូរទៅជាសិទ្ធិសង្គមតាមច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលទាំងអស់នេះជាផ្នែកមួយនៃការទទួលស្គាល់ជនជាតិដើមភាគតិចស្របតាមច្បាប់ក្នុងប្រទេសកម្ពុជា»។[៨០] មាននីតិវិធីពីរសម្រាប់ការចុះបញ្ជីដីធ្លី។ ទីមួយ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ផ្អែកតាមស្ថានភាពដែលអ្នកកាន់កាប់ដីនីមួយៗ ចាប់ផ្តើមដំណើរការចុះបញ្ជីដីធ្លី។ យន្តការនេះមិនមែនជាយន្តការដែលជនជាតិដើមភាគតិចកំពុងប្រើប្រាស់ជាទូទៅនោះទេ។ ទោះយ៉ាងណា យើងនឹងបន្តទៅការពិពណ៌នាសង្ខេប ដើម្បីមើលវឌ្ឍនភាពនៃយន្តការច្បាប់។ ជាដំបូង សេចក្តីណែនាំត្រូវបានដាក់បញ្ចូលក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ (ជាមួយមាត្រា ២០៣-២១៧)។ បន្ទាប់មកបានមកតាមអនុក្រឹត្យ និងសារាចរជាច្រើន[៨១] ដើម្បីផ្តល់នូវនីតិវិធីជាក់លាក់មួយនៃការចុះបញ្ជី រួចបង្កើនប្រសិទ្ធភាព និងសន្ទុះនៃការអនុវត្ត។ ជាចុងក្រោយ នីតិវិធីបច្ចុប្បន្នអនុញ្ញាតឱ្យ «អ្នកកាន់កាប់ដីធ្លី [ស្នើសុំ] ទៅអាជ្ញាធរចុះបញ្ជីដីធ្លីរបស់ពួកគេនៅការិយាល័យសុរិយោដីរបស់រដ្ឋ [...] ពួកគេអាចដាក់ពាក្យស្នើសុំនៅសាលាឃុំសង្កាត់ដែលអចលនទ្រព្យនោះតាំងនៅ។[៨២]

ការចុះបញ្ជីដីធ្លីប្រភេទទីពីរ គឺការចុះបញ្ជីដីធ្លីជាប្រព័ន្ធដែលគ្របដណ្តប់លើការផ្តល់បណ្ណ កម្មសិទ្ធិដីសមូហភាព។ «គម្រោងសាកល្បងធ្វើបណ្ណកម្មសិទ្ធិដីសមូហភាពបានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៣ ក្នុងគោលបំណងបង្កើតនូវអ្វីមួយដែលនោះជាអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិចដែលចុងក្រោយត្រូវបានអនុម័តនៅខែមិថុនាឆ្នាំ២០០៩»[៨៣] ដោយចាប់ផ្តើមនីតិវិធីដែលជនជាតិដើមភាគតិចកំពុងប្រើប្រាស់បច្ចុប្បន្ន។ «ប្រភេទទីពីរនេះសំដៅដល់ការចុះបញ្ជីដីក្នុងភូមិ ឬឃុំទាំងមូល»[៨៤] ដោយចាប់ផ្តើមនីតិវិធីដែលជនជាតិដើមភាគតិចកំពុងប្រើប្រាស់បច្ចុប្បន្ន ហើយអាចមានទម្រង់ជាច្រើន។ ដូចបានបង្ហាញក្នុងការស្រាវជ្រាវលើកមុនរបស់អូឌីស៊ី «ទម្រង់ទូទៅបំផុតគឺបណ្ណកម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិច»[៨៥]។ ទម្រង់ផ្សេងទៀតគឺទ្រព្យសម្បត្តិវត្តអារាម (សំណង់នៅក្នុងវត្តអារាមជាកម្មសិទ្ធិរបស់ពុទ្ធសាសនា)។[៨៦] ច្បាប់ភូមិបាលឆ្នាំ២០០១ ដែលបានចែងពីបណ្ណកម្មសិទ្ធិសមូហភាពគឺជាច្បាប់ដែលមានបញ្ហា និងមិនច្បាស់លាស់រួចទើបមានអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច និងសារាចរណែនាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទស្តីពីនីតិវិធី និងវិធីសាស្ត្រនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍ និងកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចក្នុងឆ្នាំ២០០៩។ តាមរយៈដំណើរការនេះ រដ្ឋាភិបាលចាំបាច់ត្រូវប្រកាសទីតាំងជាក់លាក់មួយសម្រាប់ធ្វើការចុះបញ្ជីនេះ។ អនុក្រឹត្យផ្តល់ព័ត៌មានលម្អិតអំពីក្របខណ្ឌដែលសហគមន៍ជនជាតិដើមភាគតិចអាចទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាព។ បន្ទាប់មកមានបីដំណាក់កាល[៨៧] ដូចបានពិពណ៌នាដោយអូឌីស៊ី៖[៨៨]

- ទីមួយ ក្រសួងអភិវឌ្ឍន៍ជនបទចេញលិខិតទទួលស្គាល់ថាសហគមន៍នោះជាសហគមន៍ជនជាតិដើមភាគតិច (គិតត្រឹមខែមិថុនា ឆ្នាំ២០១៨[៨៩] មានសហគមន៍ចំនួន ១៤១ បានទទួល)។

- ទីពីរ ក្រសួងមហាផ្ទៃចុះបញ្ជីសហគមន៍ជានីតិបុគ្គល (មានសហគមន៍ចំនួន ១២៨ បានទទួល)។

- ជាចុងក្រោយ[៩០] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះវាស់វែងដី និងចេញ បណ្ណកម្មសិទ្ធិ (មានសហគមន៍ចំនួន ២៤ បានទទួលបណ្ណកម្មសិទ្ធិដីធ្លី)។

ដំណាក់កាលចុងក្រោយនេះ រួមមានការបំពេញកាតព្វកិច្ចចុះពិនិត្យដីជនជាតិដើមភាគតិច ដែលភាគីលើដីធ្លីត្រូវសហការជាមួយមន្ត្រីសុរិយោដី ដោយបង្ហាញភស្តុតាងពាក់ព័ន្ធនឹងការកាន់កាប់ដីធ្លីនៅពេលចាប់ផ្តើមការចុះបញ្ជី។ បន្ទាប់ពីបានធ្វើការជូនដំណឹងជាមុន «មន្ត្រីទទួលខុសត្រូវលើការវាស់វែង និងកំណត់ព្រំ អាចចុះមកពិនិត្យដីក្នុងតំបន់ ដែលបានកំណត់ដើម្បីធ្វើការវាស់វែង និងកំណត់ព្រំក្បាលដីនីមួយៗ ហើយអាចអញ្ជើញម្ចាស់ដីដែលពាក់ព័ន្ធមកបំភ្លឺព្រំប្រទល់ក្បាលដីដែលខ្លួនកាន់កាប់[៩១]»។[៩២] ការវាស់វែងនេះធ្វើឡើងដើម្បីបែងចែកព្រំដីឱ្យបានច្បាស់លាស់ និងដឹងច្បាស់អំពីអត្តសញ្ញាណរបស់

អ្នកដែលរស់នៅលើដីនោះព្រោះ «មន្ត្រីទទួលបន្ទុកវិនិច្ឆ័យនឹងសាកសួរព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការកំណត់អត្ត-សញ្ញាណម្ចាស់ដី»[៩៣] ដើម្បី«បំពេញឯកសារទម្រង់ប្រមូលទិន្នន័យ»។[៩៤]

បន្ទាប់ពីការប្រមូលទិន្នន័យ «មន្ត្រីសុរិយោដីនឹងធ្វើផែនទីសន្ទស្សន៍សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីដើម្បីដាក់បញ្ចូលក្នុងបញ្ជីដីធ្លី[៩៥]»។[៩៦] ចុងក្រោយមានការបិទផ្សាយឯកសារជាសាធារណៈលើកដំបូងនៅកន្លែងមួយចំនួន (ហៅថាឯកសារនៃការវិនិច្ឆ័យ)[៩៧] ក្នុងករណីមានការតវ៉ាពីភាគីទីបីណាមួយ។ បន្ទាប់ពីនេះ ទិន្នន័យដែលប្រមូលបានទាំងអស់ត្រូវបានតម្កល់ទុកនៅរដ្ឋបាលសុរិយោដី ហើយសាធារណជនអាចចូលមើលបានដោយសេរី។

យើងអាចនិយាយអំពីស្ថានភាពជាប់គាំង[៩៨] របស់សហគមន៍ជាច្រើនដែលមានបំណងទទួលបានកម្ម-សិទ្ធិដីធ្លីនិងការតវ៉ាផ្នែករដ្ឋបាលផ្សេងៗ ទោះបីជាយើងនឹងផ្តោតលើការរំលោភលើឯកជនភាពដែលជាកង្វល់ចម្បងមួយចំពោះជនជាតិដើមភាគតិចក៏ដោយ។ ការរំលោភលើឯកជនភាពរបស់ជនជាតិដើមភាគតិចនេះជាប់ពាក់ព័ន្ធនឹងបញ្ហានៃការបំពេញការស្ទង់មតិជាមួយនឹងទិន្នន័យផ្ទាល់ខ្លួនដូចជាអត្តសញ្ញាណ (ឈ្មោះ អាយុ ភេទ) របស់មនុស្សទាំងអស់ដែលរស់នៅលើទីតាំងជាក់លាក់ណាមួយក៏ដូចជាត្រូវបានបង្ខំឱ្យឆ្លងកាត់ការស៊ើបអង្កេតជាផ្លូវការលើដីឯកជនរបស់ពួកគេ។ លក្ខខណ្ឌតម្រូវនេះអាចយោគយល់បានតាមទស្សនៈរបស់រដ្ឋបាល ប៉ុន្តែក៏មានការប៉ះពាល់ដល់ជនជាតិដើមភាគតិចផងដែរ។ ដំណើរការប្រមូលទិន្នន័យនិងការប្រើប្រាស់ជាសាធារណៈនៅពេលក្រោយ គឺជាកង្វល់មួយគួរឱ្យព្រួយបារម្ភកាន់តែខ្លាំងឡើងចំពោះជនជាតិដើមភាគតិចដែលរស់នៅលើដីព្រៃ និងភ្នំក្នុងប្រទេសកម្ពុជា។ តាមការរំពឹងទុកនឹងមានការរិះគន់កាន់តែខ្លាំងឡើងពីអ្នកតំណាងជនជាតិដើមភាគតិច។

ការរក្សាឱ្យមានតុល្យភាពរវាងឯកជនភាពរបស់ជនជាតិដើមភាគតិចនិងការផ្សព្វផ្សាយជា សាធារណៈនូវការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី (ដែលជាទិដ្ឋភាពមូលដ្ឋាននៃគោលគំនិតច្បាប់) មិនត្រូវបានកំណត់ជាអាទិភាព ឬលទ្ធ-ភាពមួយដោយសារតែមានការប្រឆាំងពីភាគីពាក់ព័ន្ធ។ ដូច្នេះ ទោះបីជាតាមទ្រឹស្តី ក្របខណ្ឌច្បាប់នៅកម្ពុជាការពារសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ក៏ដោយ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង វាត្រូវបានគេអើពើដោយគ្មានការការពារ ហើយងាយរងគ្រោះបំផុតទៅនឹងការទន្ទ្រានយកដីធ្លី និងការរំលោភបំពានពាក់ព័ន្ធ។

គេគួរតែពិចារណាទៅលើផលប៉ះពាល់នៃការសិក្សារបស់អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាតួនាទីស្នូលរបស់រដ្ឋបាលកម្ពុជាក្នុងដំណើរការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ដើម្បីទប់ស្កាត់ការរងគ្រោះដល់សហគមន៍ជនជាតិដើមភាគតិច។ មានភារកិច្ចទប់ស្កាត់ការរំលោភបំពាន ការលើកកម្ពស់ការ យល់ដឹង យុត្តិធម៌ និងធានាថា បុគ្គលិកដែលពាក់ព័ន្ធ ទទួលបានការយល់ព្រមត្រឹមត្រូវពីប្រជាពលរដ្ឋ។ គោលការណ៍ទាំងនេះគឺជាបង្គោលចរមួយឆ្ពោះទៅកាន់ក្របខណ្ឌច្បាប់ថ្មីៗជុំវិញការការពារទិន្នន័យនៅក្នុងប្រទេសកម្ពុជា។ ការយល់ដឹងជាអន្តរជាតិជុំវិញឯកជនភាព និងការការពារទិន្នន័យមានភាពរឹងមាំរួចទៅហើយ ដោយមានឯកសារពេញលេញ និងការអភិវឌ្ឍឥតឈប់ឈរនៅក្នុងច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប។ មូលដ្ឋានបញ្ញាដ៏ល្អនេះត្រូវបង្កើតនូវក្របខណ្ឌដ៏រឹងមាំមួយដើម្បីឈានទៅសម្រេចបានលទ្ធផលចុងក្រោយនៅក្នុងបទប្បញ្ញត្តិ ព្រោះវាអាចជាចំណុចរបត់មួយសម្រាប់សិទ្ធិឯកជនភាពរបស់ជនជាតិដើមភាគតិច។

# ៣. ខ្លឹមសារពាក់ព័ន្ធនៃបទប្បញ្ញត្តិថ្មីៗ របស់កម្ពុជា ស្តីពីការការពារទិន្នន័យ

ការឆ្លុះបញ្ចាំងជុំវិញការការពារទិន្នន័យនៅក្នុងប្រទេសកម្ពុជា គឺជាបញ្ហាថ្មីមួយ ហើយកំពុងត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ក្រោមឥទ្ធិពលនៃច្បាប់អន្តរជាតិ។ ខ្លឹមសារនៃច្បាប់កម្ពុជាបង្ហាញពីកង្វះប្រសិទ្ធភាពផ្លូវច្បាប់នៃការការពារទិន្នន័យកម្ពុជារួមទាំងជនជាតិដើមភាគតិចផងដែរ។ ទោះជាយ៉ាងណា តាមការជាក់ស្តែង ការការពារទិន្នន័យក្នុងវិស័យការងារនីតិបញ្ញត្តិកំពុងតែដំណើរការ ដោយសារតែមានឥទ្ធិពលជាអន្តរជាតិ។

## ក. កង្វះប្រសិទ្ធភាពនៃច្បាប់ បច្ចុប្បន្នក្នុងការការពារទិន្នន័យ របស់កម្ពុជា រួមទាំងជនជាតិដើមភាគតិច

មិនមានបទប្បញ្ញត្តិជាក់លាក់ណាមួយដែលការពារទិន្នន័យជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាទេ។ កម្ពុជាមិនទាន់បានអនុម័តច្បាប់ស្តីពីការការពារទិន្នន័យគ្រប់ជ្រុងជ្រោយណាមួយសម្រាប់ប្រជាពលរដ្ឋទេមានន័យថា បើទោះបីជាច្បាប់ខ្លះចែងអំពីការការពារទិន្នន័យក៏ដោយក៏មិនទាន់មានច្បាប់ការពារទិន្នន័យជារួមដែលមានប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជានៅឡើយដែរ។ជាការពិតណាស់ ការណ៍ដែល «ច្បាប់កម្ពុជាមិនកំណត់ជាក់លាក់នូវពាក្យ «ទិន្នន័យផ្ទាល់ខ្លួន» ឬពិភាក្សាអំពីព័ត៌មានជាក់លាក់ណាមួយដែលជាទិន្នន័យផ្ទាល់ខ្លួន»[៩៩] គឺជាឧទាហរណ៍ដ៏ល្អមួយដែលបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃក្របខណ្ឌច្បាប់។ ការញែករវាងទិន្នន័យផ្ទាល់ខ្លួន និងទិន្នន័យមិនផ្ទាល់ខ្លួននៅក្នុងប្រទេសកម្ពុជានៅតែត្រូវកំណត់ឱ្យបានត្រឹមត្រូវ ថែមទាំងទិន្នន័យផ្ទាល់ខ្លួនដែលមានលក្ខណៈរសើបផងដែរ។

ក្រៅពីមិនមានបទប្បញ្ញត្តិជាក់លាក់ស្តីពីការការពារទិន្នន័យ «មិនមានអាជ្ញាធរគ្រប់គ្រង ឬអនុវត្តណាមួយ ដែលមានភារកិច្ចពិសេសក្នុងការគ្រប់គ្រង ត្រួតពិនិត្យ ឬអនុវត្តលើបញ្ហាការពារទិន្នន័យផ្ទាល់ខ្លួននៅក្នុងប្រទេសកម្ពុជាទេ»។[១០០] យ៉ាងណាក៏ដោយ មានបទប្បញ្ញត្តិមួយចំនួនដែលផ្តល់នូវតម្រុយខ្លះអំពីអ្វីដែលអាចគ្រប់គ្រងឯកជនភាពនិងការការពារទិន្នន័យនៅកម្ពុជា។ មូលដ្ឋានផ្ទាល់នៃក្របខណ្ឌទាំងនេះរួមមានរដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីទូរគមនាគមន៍ និងច្បាប់ស្តីពីរបបសារព័ត៌មាន។ ចំណុចសំខាន់មួយដែលគួរពិចារណា គឺមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញកម្ពុជា[១០១] ស្តីពីការការពារសិទ្ធិឯកជនភាពនៃការស្នាក់នៅ និងការសម្ងាត់នៃការឆ្លើយឆ្លងតាមសំបុត្រ តេឡេក្រាម ទូរសារ ទូរលេខ និងទូរស័ព្ទ។ យោងតាមមាត្រា ៦៥ (ខ) នៃច្បាប់ស្តីពីទូរគមនាគមន៍[១០២] និងយ៉ាងច្បាស់លាស់ថា អតិថិជនមានសិទ្ធិជាមូលដ្ឋានមួយចំនួនចំពោះឯកជនភាព ដោយមិនមានបញ្ញត្តិជាក់លាក់ណាមួយស្តីពីការផ្ទេរទិន្នន័យការរក្សាទុកទិន្នន័យ ការបំពានទិន្នន័យ និងការជូនដំណឹងអំពីការបំពានទិន្នន័យឡើយ។ មាត្រា ៧ នៃច្បាប់ស្តីពីរបបសារព័ត៌មាន[១០៣] អនុវត្តជាពិសេសចំពោះកាតព្វកិច្ចរបស់អ្នកសារព័ត៌មានក្នុងការគោរពសិទ្ធិឯកជនភាពរបស់បុគ្គល។

ក្រមព្រហ្មទណ្ឌចែងអំពីការការពារទិន្នន័យជាក់លាក់ជាងនេះ បើប្រៀបធៀបទៅនឹងឧទាហរណ៍ខាងដើម។ មាត្រា៣០១[១០៤] និង ៣០២[១០៥] នៃក្រមព្រហ្មទណ្ឌ «ជាទូទៅហាមឃាត់បុគ្គលទាំងឡាយក្នុងការស្តាប់ ឬថតសំដីជាឯកជនឬថតរូបភាពនៃបុគ្គលនៅទីឯកជនដោយគ្មានការព្រមព្រៀងពីបុគ្គលដែលពាក់ព័ន្ធនោះ។

ករណីបំពានលើប្រការទាំងនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ រៀល ទៅ ២ លានរៀល»[១០៦] និងតាមមេធាវី Jay Cohen ក្នុងឆ្នាំ២០២០។ ឧទាហរណ៍បន្ថែមទៀតលើក្រមនេះ មានការដាក់ទោសទណ្ឌដូចគ្នានឹងមាត្រា ៣១៤[១០៧] ពីអាថ៌កំបាំងវិជ្ជាជីវៈ «ហាមឃាត់ការប៉ះពាល់អាថ៌កំបាំងវិជ្ជាជីវៈពីសំណាក់បុគ្គលដែលកាន់កាប់ព័ត៌មានដែលមានលក្ខណៈអាថ៌កំបាំង ដោយមូលហេតុនៃស្ថានភាពមុខរបរ មុខងារ ឬតួនាទី វិជ្ជាជីវៈ មុខងារ ឬបេសកកម្មរបស់ខ្លួន» មាត្រា ៣១៨[១០៨] ស្តីពីការសម្ងាត់ក្នុងការឆ្លើយឆ្លង និងការសន្ទនាតាមទូរសព្ទហាមឃាត់ «អំពើប្រព្រឹត្តដោយគំនិតទុច្ចរិតបើក បំផ្លាញ ការពន្យារពេល ការបង្វែរ ឬលបស្តាប់ការឆ្លើយឆ្លងដែលផ្ញើទៅកាន់ភាគីទីបី»។ មាត្រា ៣១៩[១០៩] ហាមឃាត់ «ការចាប់ ឬធ្វើឱ្យរាំងស្ទះចរាចរណ៍នៃការទំនាក់ទំនងតាមទូរសព្ទ ឬសារទូរគមនាគមន៍ណាមួយ»។

ឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មាន (អំពើចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តិនៃទិន្នន័យ) មានលក្ខណៈស្រដៀងគ្នាក្នុងលក្ខខណ្ឌនៃការដាក់ទោសទណ្ឌ លុះត្រាតែមានកត្តាធ្វើឱ្យមានស្ថានទម្ងន់ទោស ដែលនាំទៅដល់ការកាត់ទោសត្រួតគ្នាតាមមាត្រា ៤២៧ នៃក្រមព្រហ្មទណ្ឌ។[១១០] ប្រសិនបើច្បាប់ព្រហ្មទណ្ឌចែងលម្អិតកាន់តែស៊ីជម្រៅអំពីការរំលោភលើទិន្នន័យ នោះនៅតែមានវិសាលភាពត្រឹមស្ថានភាពជាក់លាក់ដែលមិនទូលំទូលាយគ្រប់គ្រាន់ ក្នុងការនិយាយអំពីការការពារទិន្នន័យឱ្យបានត្រឹមត្រូវសម្រាប់សាធារណជន ដោយមិនទាន់គិតអំពីករណីជនជាតិដើមភាគតិច។

ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់នូវ «ក្របខណ្ឌឯកជនភាពមូលដ្ឋានសម្រាប់ស្វែងរកជនសង្ស័យដែលពាក់ព័ន្ធក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ» តាមរយៈមាត្រា ៨៣ មានន័យថា រាល់ព័ត៌មានសម្ងាត់ដែលប្រមូលបានអំពីបុគ្គលនីមួយៗ នឹងត្រូវរក្សាជាការសម្ងាត់។

ជាចុងក្រោយ មាត្រា ១០ នៃក្រមរដ្ឋប្បវេណីដាក់បញ្ចូលឯកជនភាពជាសិទ្ធិផ្ទាល់ខ្លួន ខណៈដែលកំណត់គោលគំនិតនៃសិទ្ធិផ្ទាល់ខ្លួនថា «សិទ្ធិផ្ទាល់ខ្លួនរួមមានសិទ្ធិមានជីវិតរស់នៅ សិទ្ធិមានសុវត្ថិភាពផ្ទាល់ខ្លួន សុខភាព សេរីភាព អត្តសញ្ញាណ ឯកជនភាព និងអត្ថប្រយោជន៍ និងផលប្រយោជន៍ផ្សេងៗ»។ បញ្ញត្តិច្បាប់នេះអាចត្រូវបានបកស្រាយថា ជាការការពារទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗដែលជាផ្នែកមួយនៃសិទ្ធិឯកជនភាព។ មាត្រា ១១ នៃក្រមរដ្ឋប្បវេណី ចែងពីសិទ្ធិក្នុងការទទួលបានដីកាសម្រេចរក្សាការពារក្នុងស្ថានភាពដែលមានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងហៀបនឹងមានគ្រោះថ្នាក់ ដែលអាចបញ្ឈាក់ពីការរំលោភសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គលនោះ។

ជាការសន្និដ្ឋានលើក្រមរដ្ឋប្បវេណី មាត្រា ១២ អាចត្រូវបានសន្មតថាជាបញ្ញត្តិច្បាប់មួយសម្រាប់បុគ្គលម្នាក់ៗក្នុងការស្វែងរកដីកាសម្រេចរក្សាការពារ ជាតួយ៉ាង ឱ្យលុបចោលការផ្ទុកទិន្នន័យផ្ទាល់ខ្លួនរបស់ខ្លួនដែលប្រមូលបានដោយខុសច្បាប់។

គេរកមិនឃើញយន្តការគ្រប់គ្រង ឬយន្តការច្បាប់ដែលមានប្រសិទ្ធភាពពីច្បាប់មួយចំនួនតូចនេះទេ ដោយសារច្បាប់ទាំងនោះភាគច្រើនមានភាពស្រពិចស្រពិលខ្លាំង និងមិនផ្តល់មូលដ្ឋានច្បាប់គ្រប់គ្រាន់ ដូច្នេះហើយ «គ្មានច្បាប់ណាមួយមានខ្លឹមសារសារធាតុទេ»[១១១] និង «គ្មានច្បាប់ណាមួយទាំងមានបញ្ញត្តិ (ឬមានវិសាលភាពទូលំទូលាយគ្រប់-គ្រាន់) ចែងពីការប្រមូល រក្សាទុក និងដំណើរការ ទិន្នន័យ ឯកជនភាព និងផ្ទាល់ខ្លួននោះទេ»។[១១២]

ទោះជាយ៉ាងណា គេរំពឹងថានឹងមានវឌ្ឍនភាពសំខាន់ៗ លើវិស័យច្បាប់ទាំងនេះ។ ឧទាហរណ៍ថ្មី មួយបង្ហាញពីភាពប្រសើរឡើងយ៉ាងច្បាស់ជាមួយនឹងប្រភេទច្បាប់ដែលចែងលម្អិតជាងនេះ នោះគឺច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក[១១៣] «ដែលមានបញ្ញត្តិការពារទិន្នន័យអ្នកប្រើប្រាស់ដែលប្រមូលបានក្នុងអំឡុងពេលទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក»។[១១៤] ជាចុងក្រោយ ច្បាប់នេះកំណត់អំពី «ទិន្នន័យ»។ ជាអកុសលមិនមានការកំណត់និយមន័យនៃពាក្យទិន្នន័យផ្ទាល់ខ្លួន ឬការការពារទិន្នន័យបែបនេះទេ។ ជាទូទៅ បទប្បញ្ញត្តិថ្មីនេះមានវិសាលភាពអនុវត្តចំពោះអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានកាតព្វកិច្ចទូទៅក្នុងការទទួលបានការយល់ព្រមជាមុនពីអ្នកប្រើប្រាស់មុនពេល

ប្រមូល និងរក្សាទុកទិន្នន័យផ្ទាល់ខ្លួន។ មិនមានការកំណត់ពេលវេលានៃការរក្សាទុកទិន្នន័យ និងកាតព្វកិច្ចជាសកលសម្រាប់ «វិធានការសុវត្ថិភាពសមស្រប ដើម្បីជៀសវាងការបាត់បង់ ការកែប្រែ ការលេចធ្លាយ និង/ឬការលួចបញ្ចេញទិន្នន័យអ្នកប្រើប្រាស់ទាំងអស់» យោងតាមមាត្រា ៣២។ ទាក់ទងនឹងការដាក់ទោសទណ្ឌ ការបំពានទិន្នន័យអាចនាំទៅដល់ការដកហូត ឬព្យួរអាជ្ញាបណ្ណពាក់ព័ន្ធ ការដាក់ទោសជាប់ពន្ធនាគារពីមួយខែដល់បីឆ្នាំ និង/ឬការពិន័យជាប្រាក់ពី ១០០.០០០រៀល ទៅ ១០ លានរៀល។ ទោះបីជាវាមានតួនាទីសំខាន់តាមរយៈអត្ថបទនេះក៏ដោយ ក៏ច្បាប់នេះ«មានកម្រិតវិសាលភាពត្រឹមការការពារទិន្នន័យនិម្មិត និង/ឬឌីជីថលប៉ុណ្ណោះ»។[១១៩] ទោះយ៉ាងណាវិសាលភាពចងភ្ជាប់តាមផ្លូវច្បាប់នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺមិនច្បាស់លាស់ ហើយត្រូវការការបញ្ជាក់ខ្លះៗ។

ទោះបីជាមានការវិវឌ្ឍថ្មីៗ ជុំវិញគោលនយោបាយការពារទិន្នន័យ និងការទទួលស្គាល់កាន់តែខ្លាំងឡើងនូវសិទ្ធិឯកជនភាពក៏ដោយ ក៏ការងារចាំបាច់ភាគច្រើនមិនទាន់ត្រូវបានធ្វើនៅឡើយ។ គ្មានបទប្បញ្ញត្តិសាធារណៈណាមួយ ហាក់ដូចជាមានប្រយោជន៍ក្នុងការការពារសិទ្ធិឯកជនភាពរបស់ជនជាតិដើមភាគតិចទេ។ បទប្បញ្ញត្តិការពារទិន្នន័យ មិនមានវិសាលភាពគ្របដណ្តប់លើការប្រមូលទិន្នន័យទេ ដែលស្តែងឡើងតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ឬនីតិវិធីរដ្ឋបាលចុះបញ្ជីដីធ្លី។ ជាចុងក្រោយ ទិន្នន័យជនជាតិដើមភាគតិចពិតជាមិនត្រូវបានការពារពីច្បាប់ការពារទិន្នន័យទល់នឹងការរំលោភលើឯកជនភាពណាមួយ ក្នុងក្របខណ្ឌច្បាប់ទូទៅនៅក្នុងប្រទេសកម្ពុជានោះទេ។ សំខាន់ជាងនេះទៀត គេពុំឃើញមានបទប្បញ្ញត្តិជាក់លាក់ណាមួយដែលចែងអំពីអធិបតេយ្យភាពទិន្នន័យជនជាតិដើមភាគតិចនោះទេ សូម្បីតែនៅពេលនេះក៏ដោយ។ ដូចគ្នានឹងដំណើរការចុះបញ្ជីដីសមូហភាពនៅទូទាំងពិភពលោកដែរដែលមិនបានជួយ និងផ្តល់ការការពារផ្លូវច្បាប់លើទឹកដីជនជាតិដើមភាគតិច និងការរស់នៅរបស់ពួកគេ ការការពារទិន្នន័យនៅក្នុងប្រទេសកម្ពុជាមិនអាចផ្តល់ការគាំទ្រ ឬការពារអធិបតេយ្យភាពទិន្នន័យជនជាតិដើមភាគតិចទេនាពេលនេះ។ ទោះបីជាភាគច្រើនបទប្បញ្ញត្តិដែលទាក់ទងនឹងទិន្នន័យ និងឯកជនភាព មិនទាន់អាចអនុវត្តបានតាមច្បាប់ក៏ដោយ ក៏នៅមានក្តីសង្ឃឹមមួយចំនួនតាមរយៈឥទ្ធិពលយ៉ាងខ្លាំងនៃច្បាប់អន្តរជាតិ និងតំបន់។

## ខ. ដំណើរការនៃការងារផ្នែកច្បាប់ការពារទិន្នន័យ និងឥទ្ធិពលអន្តរជាតិមកលើនីតិរដ្ឋកម្ពុជាដែលកំពុងតែមានវឌ្ឍនភាព

ការវិវត្តចុងក្រោយបង្អស់មួយចំនួនលើការការពារទិន្នន័យក្នុងប្រទេសកម្ពុជា បង្ហាញពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យការពារទិន្នន័យ។ គេរំពឹងថានឹងមានវឌ្ឍនភាពបន្ថែមទៀតលើការការពារទិន្នន័យ ដូចជាវិសាលភាពការងារដែលកំពុងដំណើរការលើសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត «ដែលមានខចែងអំពីការការពារទិន្នន័យជាក់លាក់ ទាក់ទងនឹងការរក្សាទុកទិន្នន័យក្នុងអំឡុងពេលស៊ើបអង្កេតឧក្រិដ្ឋកម្ម ការស្វែងរក និងរឹបអូសទិន្នន័យកុំព្យូទ័រសម្រាប់ប្រើប្រាស់ជាភស្តុតាង និងការការពារដីមានសក្តានុពលសម្រាប់ជនសង្ស័យដើម្បីរារាំងការរំលោភលើឯកជនភាពទិន្នន័យ [...] ចារកម្មទិន្នន័យ ការស្ទាក់ចាប់ដោយខុសច្បាប់នូវការបញ្ជូនទិន្នន័យកុំព្យូទ័រមិនមែនសាធារណៈ និងការជ្រៀតជ្រែកទិន្នន័យ ។ល។» ទោះបីជាយ៉ាងណា បទប្បញ្ញត្តិនេះបានផ្អាកដំណើរការបន្ថែមទៀតចាប់តាំងពីឆ្នាំ២០១៦ ដែលបង្ហាញពីការលំបាកសម្រាប់បទប្បញ្ញត្តិថ្មីនៅក្នុងក្របខណ្ឌការពារទិន្នន័យ។

សមាគមមួយចំនួនបានសម្តែងការព្រួយបារម្ភជុំវិញការវិវឌ្ឍនៃការការពារទិន្នន័យ ខណៈកំពុងធ្វើការវិភាគលើអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ។ ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤២ ផ្សេងទៀត មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និង IFEX បានព្រមានថាឧបករណ៍នីតិប្បញ្ញត្តិនឹងរំលោភលើ «កាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា និងរដ្ឋធម្មនុញ្ញរបស់ខ្លួន ដោយ

ការគំរាមកំហែងសិទ្ធិមនុស្សទាំងនៅក្នុងបណ្តាញ និងក្រៅបណ្តាញនៅកម្ពុជា ជាពិសេសសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន និងឯកជនភាព»។[១១៦] ការវិភាគរហ័សលើមាត្រា ១៤ នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ (NIG) លើកឡើងនូវចម្ងល់អំពីហានិភ័យដែលអាចកើតមានចំពោះការការពារទិន្នន័យ និងការរក្សាការសម្ងាត់ទិន្នន័យ ដោយសារវាចែងពីការរក្សាទុកទូទៅ និងការចែករំលែកទិន្នន័យផ្ទាល់ខ្លួន។ រាជរដ្ឋាភិបាលកម្ពុជាកំពុងបង្កើតប្រព័ន្ធមួយសម្រាប់ប្រមូលផ្តុំទិន្នន័យផ្ទាល់ខ្លួនតាមរយៈក្រុមហ៊ុនតាមវិធីទូលំទូលាយ និងគ្មានដែនកំណត់ដែលបង្កគ្រោះថ្នាក់ដល់សិទ្ធិឯកជនភាពអន្តរជាតិ (មាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដាក់បញ្ចូលសិទ្ធិទទួលបានការការពារទិន្នន័យផ្ទាល់ខ្លួន)។ អនុក្រឹត្យនេះមិនបានផ្តល់នូវ «បញ្ជីច្បាស់លាស់នៃប្រភេទព័ត៌មាន ឬទិន្នន័យដែលអាចរក្សាទុក និងចែករំលែកបាន បែរជាបញ្ចូលបញ្ញត្តិដែលមិនច្បាស់លាស់ស្តីពី «ព័ត៌មានផ្សេងទៀតតាមការតម្រូវ» ដែលតាមរយៈនេះ ក្រុមហ៊ុនអាចត្រូវបានរដ្ឋាភិបាលតម្រូវឱ្យផ្តល់សិទ្ធិប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនណាមួយតាមការតម្រូវ»។[១១៧] កង្វះការការពារសុវត្ថិភាពក្នុងការការពារសិទ្ធិបុគ្គលជារឿងមួយគួរឱ្យព្រួយបារម្ភដែលអាចចាត់ទុកជាការបំពានរដ្ឋធម្មនុញ្ញប្រឆាំងនឹងសិទ្ធិបុគ្គលរបស់កម្ពុជា។

មួយជ្រុងនៃការកត់សម្គាល់គឺថា ការអនុវត្តប្រព័ន្ធបែបនេះមិនស្របតាមលក្ខខណ្ឌគ្រប់គ្រាន់ណាមួយនៃការការពារសុវត្ថិភាពទិន្នន័យនោះទេ។ ដូច្នេះ វាបង្កើនហានិភ័យយ៉ាងខ្លាំងចំពោះសុវត្ថិភាពទិន្នន័យពីការជ្រៀតជ្រែករបស់ភាគីទីបី ឬក្រុមចោរកម្មព័ត៌មាន។ ដូចអ្វីដែល IFEX បានរៀបរាប់ «ការប្រមូលផ្តុំចរាចរអ៊ីនធឺណិត និងទិន្នន័យក្រោមអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិបង្កើតចំណុចស្នូលមួយដែលបង្កឱ្យមានភាពងាយរងគ្រោះពីសំណាក់តួអង្គដែលមានចេតនាមិនល្អ ខណៈដែលការតម្រូវឱ្យរក្សាទុកទិន្នន័យដោយមិនធានានូវសមត្ថភាពរបស់អ្នកផ្តល់សេវាក្នុងការដោះស្រាយឱ្យបានគ្រប់គ្រាន់នូវការកើនឡើងជាលទ្ធផលនៃតម្រូវការសុវត្ថិភាពទិន្នន័យកាន់តែធ្វើឱ្យហានិភ័យនេះមានសភាពធ្ងន់ធ្ងរឡើង»។[១១៨]

តាមរយៈព័ត៌មានថ្មីៗ ពីប្រភេទរដ្ឋាភិបាល បង្ហាញថា ក្រុមមេធាវីរបស់ក្រសួងមហាផ្ទៃ និងក្រុមអ្នកឯកទេសផ្នែកទិន្នន័យកំពុងធ្វើការលើសេចក្តីព្រាងដំបូងនៃអនុក្រឹត្យស្តីពីការគ្រប់គ្រង ការប្រើប្រាស់ ការការពារឯកជនភាព និងសុវត្ថិភាពទិន្នន័យដែលរដ្ឋាភិបាលប្រមូលបានសម្រាប់ប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណបុគ្គល។ អាស្រ័យហេតុនេះ លោក ប៊ុន ហ៊ុន រដ្ឋលេខាធិការក្រសួង និងជាប្រធានក្រុមប្រឹក្សានីតិកម្ម បានមានប្រសាសន៍ថា ពួកគេកំពុងព្យាយាមរួមគ្នាក្នុងការកំណត់វិធានស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការពារឯកជនភាព ក្នុងការកំណត់អត្តសញ្ញាណទិន្នន័យដើម្បីជាប្រយោជន៍សាធារណៈ លើកកម្ពស់គុណភាពសេវា និងអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើន ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់។ ដូច្នេះហើយ មន្ត្រីជាន់ខ្ពស់រូបនេះបានប្រកាសថា ជាក់ស្តែងណាស់មានការលំបាកមួយចំនួនដោយសារតែ «បច្ចុប្បន្ន ទិន្នន័យ និងអត្តសញ្ញាណរបស់បុគ្គលអាចត្រូវបានប្រមូលយក និងប្រើប្រាស់ដោយគ្មានការធានាលើការការពារឯកជនភាព ឬសុវត្ថិភាពនៃទិន្នន័យរបស់ពួកគេនិងដោយគ្មានការការពារតាមផ្លូវច្បាប់»។[១១៩]

មន្ត្រីជាន់ខ្ពស់រូបនេះ បានសារភាពដោយបើកចំហអំពីភាពធ្ងន់ធ្ងរនៃស្ថានភាពទិន្នន័យ និងចំណុចខ្សោយជាក់ស្តែងនៃបទប្បញ្ញត្តិកម្ពុជា។ ជាការឆ្លើយតបគណៈកម្មាធិការការងារបាននិងកំពុងកែសម្រួលអនុក្រឹត្យនេះឡើងវិញដើម្បីសម្រួលដល់ច្បាប់ការពារទិន្នន័យនាពេលអនាគត។ លោក តុប នេត អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មផ្តល់ការណែនាំ និងព្រមានអំពីតម្រូវការបទប្បញ្ញត្តិច្បាស់លាស់ក្នុងវិសាលភាពនៃអនុក្រឹត្យ។ ក្រុមអ្នកជំនាញក៏ត្រូវពិនិត្យមើលឱ្យបានត្រឹមត្រូវនូវអ្វីដែលជាទិន្នន័យផ្ទាល់ខ្លួន[១២០] និងការរក្សាទុកទិន្នន័យដែលមានអត្តសញ្ញាណបុគ្គល ឬការប្រើប្រាស់ដោយសុវត្ថិភាពដោយមិនប៉ះពាល់ដល់ឯកជនភាពរបស់ពួកគេ។ លោកសានជ័យ នាយកប្រតិបត្តិអង្គការសម្ព័ន្ធគណនេយ្យភាពសង្គម បានគូសបញ្ជាក់អំពីតម្រូវការឱ្យមានភាពស៊ីសង្វាក់គ្នាដោយពិចារណាទៅលើសិទ្ធិឯកជនភាពរបស់បុគ្គលព្រោះនោះជាគោលការណ៍ណែនាំដែលគួរត្រូវដាក់បញ្ចូលទៅក្នុងគោលនយោបាយឌីជីថលរបស់រដ្ឋាភិបាល។ គោលនយោបាយឌីជីថលរបស់រដ្ឋាភិបាល គឺជាគំនិតថ្មី

មួយនៅកម្ពុជា ទោះបីជារដ្ឋាភិបាលបាននិងកំពុងតែដំណើរការរួចហើយនូវសេចក្តីព្រាងនៃក្របខណ្ឌគោលនយោបាយឆ្នាំ២០២១ - ២០៣៥ សម្រាប់បរិយាកាសសេដ្ឋកិច្ចសង្គមឌីជីថលរបស់កម្ពុជាដែលកំពុងមានការវិវត្ត ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក៏ដោយ។[១២១]

ដោយសាររដ្ឋាភិបាលកំពុងធ្វើការលើការកសាងប្រព័ន្ធការពារទិន្នន័យ ដែលកាន់តែមានប្រសិទ្ធភាព ហើយនៅពេលដែលគោលនយោបាយការពារទិន្នន័យជាតិដ៏ត្រឹមត្រូវមួយកំពុងតែលេចចេញជារូបរាង នោះឥទ្ធិពលនៃច្បាប់ក្នុងតំបន់ និងអន្តរជាតិមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍបទប្បញ្ញត្តិរបស់កម្ពុជា។

ឥទ្ធិពលបុរេសកម្ម និងប្រកបដោយបរិយាប័ន្ននៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)[១២២] គឺជាមូលដ្ឋានគ្រឹះក្នុងការធ្វើទំនើបកម្មនៃគោលនយោបាយការពារទិន្នន័យនៅកម្ពុជា។ អាស៊ានទើបតែសម្រេចបាននូវសមិទ្ធផលដ៏សំខាន់មួយតាមរយៈកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ាន ក្របខណ្ឌស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួនក្នុងឆ្នាំ២០១២ ដែលត្រូវបានអនុម័តកាលពីខែវិច្ឆិកា ឆ្នាំ២០១៦។ គោលបំណងនៃក្របខណ្ឌនេះ គឺដើម្បីកសាងមូលដ្ឋានរួមមួយសម្រាប់សមាជិកលើវិស័យការពារទិន្នន័យ ដែលសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងជារួមដើម្បីពង្រឹងការការពារទិន្នន័យផ្ទាល់ខ្លួននៅក្នុងរង្វង់អាស៊ាន ដោយវានឹងជួយលើកកម្ពស់កំណើនពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក និងលំហូរព័ត៌មាន។ សេចក្តីប្រកាសចែងថា «អ្នកចូលរួមទទួលស្គាល់ពីតម្រូវការការពារ និងទប់ស្កាត់ការប្រើប្រាស់មិនសមស្របនូវទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គល ហើយព្យាយាមគិតគូរ និងអនុវត្តនៅក្នុងច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួននូវគោលការណ៍ការពារទិន្នន័យផ្ទាល់ខ្លួនខាងក្រោម ('គោលការណ៍') អនុលោមតាមក្របខណ្ឌនេះ»។[១២៣] គោលការណ៍ទាំងនេះរួមមាន៖ «ការយល់ព្រម ការជូនដំណឹង និងគោលបំណង ភាពត្រឹមត្រូវនៃទិន្នន័យផ្ទាល់ខ្លួន ការការពារសុវត្ថិភាព ការចូលប្រើប្រាស់ និងការកែតម្រូវ ការផ្ទេរទៅកាន់ប្រទេសឬដែនដីមួយផ្សេងទៀត ការរក្សាទុក និងគណនេយ្យភាព»។ ឧទាហរណ៍នៃកិច្ចសហប្រតិបត្តិការនេះ បង្ហាញឱ្យឃើញពីចលនាទូទៅឆ្ពោះទៅរកការការពារទិន្នន័យកាន់តែប្រសើរឡើង រួមទាំងនៅកម្ពុជាក្នុងនាមជាសមាជិកអាស៊ានផងដែរ។ ទោះជាយ៉ាងណាវាពិបាកក្នុងការបង្កើតសន្ទុះផ្នែកច្បាប់ពិតប្រាកដជុំវិញគំនិតផ្តួចផ្តើមអាស៊ានតែម្នាក់ឯង ការអភិវឌ្ឍ «បទប្បញ្ញត្តិការពារទិន្នន័យក្នុងអាស៊ានរហូតមកដល់ពេលនេះគឺមានភាពរដិបរដុប»។[១២៤] ក្នុងចំណោមប្រទេសចំនួន ១០ មានតែប្រទេសចំនួន ៤ ប៉ុណ្ណោះដែលមានច្បាប់ការពារទិន្នន័យផ្ទាល់ខ្លួនត្រឹមត្រូវ (ប្រទេស សិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន និងថៃដែលទើបតែមាន)។[១២៥] ក្នុងករណីកម្ពុជា អ្នកជំនាញមកពីបណ្តាញ ASEAN INSIDERS កំណត់ថា«មានកិច្ចខិតខំប្រឹងប្រែងទ្រង់ទ្រាយតូចបានធ្វើឡើងនៅតាមធនាគារ ក្រុមហ៊ុនច្បាប់ និងក្រុមហ៊ុនធានារ៉ាប់រង ដើម្បីអនុវត្តតាមបទប្បញ្ញត្តិការពារទិន្នន័យទូទៅរបស់សហភាពអឺរ៉ុបនៅក្នុងគោលនយោបាយក្រុមហ៊ុនរបស់ពួកគេ»។[១២៦] នេះបង្ហាញថា ទោះបីជាមានទិសដៅឆ្ពោះទៅរកគោលនយោបាយការពារទិន្នន័យក៏ដោយ ប៉ុន្តែនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។

ច្បាប់តំបន់អឺរ៉ុបក៏មានឥទ្ធិពលខ្លះៗ មកលើប្រទេសកម្ពុជាផងដែរ។ បទប្បញ្ញត្តិការពារទិន្នន័យទូទៅរបស់សហភាពអឺរ៉ុបមានឥទ្ធិពលដោយផ្ទាល់មកលើគោលនយោបាយរបស់តួអង្គក្នុងវិស័យឯកជនក្នុងប្រទេសកម្ពុជា (ដោយសារពួកគេមានបំណងអនុវត្តតាមបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុបដើម្បីគាំទ្រពាណិជ្ជកម្ម) និងដោយប្រយោលមកលើប្រទេសកម្ពុជាជាមួយនឹងឥទ្ធិពលដ៏ច្របូកច្របល់តាមរយៈគោលនយោបាយអាស៊ានធ្វើឱ្យប៉ះពាល់ដល់ប្រទេសកម្ពុជា។ បទប្បញ្ញត្តិការពារទិន្នន័យទូទៅ បានដាក់ឱ្យប្រើប្រាស់នូវបទដ្ឋានខ្ពស់ ច្បាប់តឹងរ៉ឹង និងការដាក់ទណ្ឌកម្មកាន់តែតឹងរ៉ឹងនៅក្នុងសហភាពអឺរ៉ុប ជាមួយនឹងការអនុវត្តនៅក្រៅដែនដី។ ទន្ទឹមនឹងនេះដែរ បទប្បញ្ញត្តិអឺរ៉ុបកំពុងត្រួតពិនិត្យលើ «ការប្រើប្រាស់ទិន្នន័យពលរដ្ឋរបស់ខ្លួនពីសំណាក់ក្រុមហ៊ុនទាក់ទងនឹងទិន្នន័យឯកជនភាព សុវត្ថិភាព និងតម្លាភាព មិនត្រឹមតែនៅក្នុងតំបន់របស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏មានក្រុមហ៊ុន ឬស្ថាប័ននានាទូទាំងពិភពលោកដែលដំណើរការ ឬរក្សាទុកទិន្នន័យរបស់ប្រជាជនរស់នៅសហភាពអឺរ៉ុបផងដែរ»។[១២៧] ដោយទទួលស្គាល់ថាអាស៊ានជាដៃគូពាណិជ្ជកម្មដ៏សំខាន់ជាមួយអឺរ៉ុប «បណ្តាប្រទេសអាស៊ានជាច្រើនកំពុងពិនិត្យមើលច្បាប់ការពារទិន្ន-

ន័យផ្ទាល់ខ្លួនរបស់ពួកគេ ហើយអាចបង្កើតក្របខណ្ឌបទប្បញ្ញត្តិស្រដៀងគ្នា ដើម្បីការពារពលរដ្ឋរបស់ខ្លួន និងអនុញ្ញាតឱ្យអាជីវកម្មក្នុងស្រុកអាចដំណើរការជាសកលតាមរយៈប្រភេទមួយចំនួននៅក្នុងអភិក្រមនៃបទប្បញ្ញត្តិ»។[១២៨] ឧទាហរណ៍មួយចំនួននិយាយតែចំពោះខ្លួនឯងជាជាងត្រួតពិនិត្យនូវច្បាប់ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួនឆ្នាំ២០១០ របស់ប្រទេសម៉ាឡេស៊ី ដើម្បីឱ្យស្របតាមបទដ្ឋានបទប្បញ្ញត្តិការពារទិន្នន័យទូទៅរបស់អឺរ៉ុប។ ច្បាប់ការពារទិន្នន័យផ្ទាល់ខ្លួនឆ្នាំ២០១២ របស់សិង្ហបុរីដាក់បញ្ចូលនូវគោលការណ៍មួយចំនួននៃបទប្បញ្ញត្តិការពារទិន្នន័យទូទៅរបស់សហភាពអឺរ៉ុប (ដូចជាការយល់ព្រមពីអតិថិជនលើការប្រមូល ដំណើរការ និងការបង្ហាញទិន្នន័យ)។ ក្នុងការរៀបចំច្បាប់ស្តីពីឯកជនភាពទិន្នន័យរបស់ហ្វីលីពីនក្នុងឆ្នាំ២០១៦ និយតករហ្វីលីពីនបានស្នើសុំការណែនាំដើម្បីធានាបាននូវការអនុលោមតាមច្បាប់ឯកជនភាពទិន្នន័យ។

សមិទ្ធផលចុងក្រោយបង្អស់របស់អាស៊ានក្នុងវិស័យនេះ គឺការអនុម័តលើក្របខណ្ឌគ្រប់គ្រងទិន្នន័យថ្មី (DMF) និងគំរូខកិច្ចសន្យាសម្រាប់លំហូរទិន្នន័យឆ្លងព្រំដែន (MCCs) កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១។ ឯកសារទាំងពីរនេះពង្រឹង និងលើកកម្ពស់នូវសុខដុមរមនីយកម្មនៃលំហូរទិន្នន័យ និងការអនុវត្តអភិបាលកិច្ចទិន្នន័យទូទាំងអាស៊ីអាគ្នេយ៍។ មិនមានកាតព្វកិច្ចសម្រាប់រដ្ឋជាសមាជិកក្នុងការអនុម័តឯកសារទាំងនេះទេ ទោះបីជាគោលបំណងគឺដើម្បីប្រមូលផ្តុំសមាជិកទាំងអស់ជុំវិញបុព្វហេតុនោះក៏ដោយ។

ពិសេសជាងនេះទៀត ក្របខណ្ឌគ្រប់គ្រងទិន្នន័យ «ត្រូវបានរៀបចំឡើងដើម្បីផ្តល់ការណែនាំជាក់ស្តែងសម្រាប់វិស័យអាជីវកម្មឯកជនទាំងអស់ ដែលកំពុងធ្វើប្រតិបត្តិការក្នុងរដ្ឋសមាជិកអាស៊ានណាមួយ និងជួយដល់ពួកគេអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យដោយផ្អែកលើការអនុវត្តការគ្រប់គ្រងល្អ និងគោលការណ៍ជាមូលដ្ឋានដោយប្រើវិធីសាស្ត្រផ្អែកលើហានិភ័យ» នេះបើយោងតាមក្រុមអ្នកជំនាញ Lexology ។ យន្តការនេះមានធាតុផ្សំជាមូលដ្ឋានចំនួនប្រាំមួយ៖ «អភិបាលកិច្ច និងការត្រួតពិនិត្យ គោលនយោបាយ និងឯកសារនីតិវិធី បញ្ជីសារពើភណ្ឌទិន្នន័យ ការវាយតម្លៃផលប៉ះពាល់/ហានិភ័យ ការត្រួតពិនិត្យ ការតាមដាន និងកែលម្អជាបន្តបន្ទាប់»។[១២៩] ក្របខណ្ឌគ្រប់គ្រងទិន្នន័យត្រូវបានសន្មតថានាំមកនូវតម្លាភាព និងការជឿទុកចិត្តគ្នាទៅវិញទៅមករវាងបុគ្គល និងក្រុមហ៊ុនបរទេសក្នុងការអនុវត្តអាជីវកម្មប្រកបដោយនិរន្តរភាព។

គំរូខសន្យាសម្រាប់លំហូរទិន្នន័យឆ្លងដែនក៏កំពុងជួយសម្រួលដល់អាជីវកម្មតាមរយៈ «កិច្ចព្រមព្រៀងលក្ខខណ្ឌនៃកិច្ចសន្យាដែលទាក់ទងនឹងការផ្ទេរទិន្នន័យផ្ទាល់ខ្លួនឆ្លងដែនរវាងអាជីវកម្មក្នុងតំបន់ មានន័យថាដើម្បីដាក់បញ្ចូលកាតព្វកិច្ចការពារទិន្នន័យសំខាន់ៗ និងកាត់បន្ថយការចំ-ណាយលើការចរចា និងការអនុលោមតាមច្បាប់»[១៣០] និងបង្កភាពងាយស្រួលក្នុងការកំណត់ទំនួលខុសត្រូវ និងកាតព្វកិច្ចរបស់ភាគីនានាក្នុងការការពារទិន្នន័យ។

ការអនុវត្តឧបករណ៍ថ្មីទាំងពីរនេះ អាចនាំឱ្យមានការអនុវត្តការការពារទិន្នន័យកាន់តែច្រើនឡើងនៅក្នុងវិស័យអាជីវកម្ម ដោយត្រួសត្រាយផ្លូវ សម្រាប់ការបង្កើតច្បាប់ផ្សេងទៀត។

ជាការសន្និដ្ឋានលើវិសាលភាពនៃឥទ្ធិពលរបស់អាស៊ាន គេឃើញយ៉ាងច្បាស់ថាស្ថាប័ននេះនាំមកនូវបរិយាកាសទំនើបកម្ម និងភាពស៊ីសង្វាក់គ្នា អូសទាញប្រទេសទាំងអស់ក្នុងតំបន់រួមទាំងប្រទេសកម្ពុជា ដើម្បីកែលម្អប្រព័ន្ធច្បាប់របស់ខ្លួនជុំវិញការការពារទិន្នន័យ ការកែលម្អកំណើន និងសិទ្ធិមនុស្សដែលអាចផ្តល់ផលប្រយោជន៍ដល់ជនជាតិដើមភាគតិចផងដែរ។

# ៤. សេចក្តីសន្និដ្ឋាន

ស្ថានភាពរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន មិនផ្តល់ជនជាតិដើមភាគតិចនូវឋានៈដែលមានសិទ្ធិអំណាចនោះទេ។ ជាក់ស្តែងណាស់ កង្វល់របស់ពួកគេអំពីការទទួលបានដីធ្លី និងការការពារទិន្នន័យមិនត្រូវបានផ្តល់អាទិភាពពីរដ្ឋនោះទេ ដោយរដ្ឋាភិបាលផ្តោតជាសំខាន់លើការអភិវឌ្ឍសេដ្ឋកិច្ច។ ទោះជាយ៉ាងណា ការវិវឌ្ឍចុងក្រោយបង្អស់នូវប្រព័ន្ធច្បាប់កម្ពុជាកំពុងបង្ហាញពីភាពយឺតយ៉ាវនៃចលនាមួយឆ្ពោះទៅរកទំនើបកម្មនៃការការពារទិន្នន័យ ហើយជាសក្តានុពលជួយដល់ជនជាតិដើមភាគតិច និងឆ្ពោះទៅរកអធិបតេយ្យភាពនៃទិន្នន័យជនជាតិដើមភាគតិច។

ជាក់ស្តែង ឥទ្ធិពលក្នុងតំបន់ និងអន្តរជាតិបាននិងកំពុងជួយតាមរយៈចលនាសុខដុមនីយកម្មផ្នែកច្បាប់ដែលបង្កលក្ខណៈងាយស្រួលដល់ការដោះដូរពាណិជ្ជកម្ម។ ជាចុងក្រោយ ករណីជនជាតិដើមភាគតិចគ្រាន់តែជាឧទាហរណ៍មួយនៃការតស៊ូដើម្បីឱ្យមានការការពារទិន្នន័យកាន់តែទូលំទូលាយប៉ុណ្ណោះ ប៉ុន្តែបរិបទជនជាតិដើមភាគតិចទាមទារឱ្យមានការបោះជំហានបន្ថែមទៀតដើម្បីកំណត់អត្តសញ្ញាណការការពារជាក់លាក់ និងសមស្រប។ ការការពារទិន្នន័យនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាគឺជាមូលដ្ឋានមួយនៃដំណើរការខ្លះៗ នៃបទប្បញ្ញត្តិផ្សេងៗ ដែលគ្រាន់តែកំណត់និយមន័យទិន្នន័យ ហើយគ្រាន់តែចាប់ផ្តើមទទួលស្គាល់ និងការពារសិទ្ធិប៉ុណ្ណោះ។ មានការងារជាច្រើនដែលត្រូវធ្វើឱ្យសម្រេចបាននៅថ្ងៃណាមួយ ក្នុងការការពារដោយត្រឹមត្រូវនូវទិន្នន័យជនជាតិដើមភាគតិច។

# ឯកសារយោង




១. អង្គការសហប្រជាជាតិ. វេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើមភាគតិច សម័យប្រជុំលើកទី៦ ថ្ងៃទី១៤-២៥ ខែឧសភា ឆ្នាំ២០០៧. http://www.un.org/esa/socdev/unpfii/documents/6_session_ tebtebba_iwgia.pdf, បានចូលមើលនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២១។

២. របាយការណ៍ ម.ស.ម.ក "ការទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិចនៅកម្ពុជា" ("របាយការណ៍") https://cchrcambodia.org/admin/media/report/report/english/2016_02_11_CCHR_Report_Access_to_Collective_Land_Titles_ENG.pdf បានចូលមើលនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២១។

៣. ១ IWGIA, 'ពិភពជនជាតិដើមភាគតិចឆ្នាំ២០០៦' (២០០៦) http://bit.ly/21bgrsZ

៤. របាយការណ៍ ម.ស.ម.ក "សិទ្ធិទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិចនៅកម្ពុជា" ("របាយការណ៍"), https://cchrcambodia.org/admin/media/report/report/english/2016_02_11_CCHR_Report_Access_to_Collective_Land_Titles_ENG.pdf ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១។

៥. របាយការណ៍ ម.ស.ម.ក "សិទ្ធិទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិចនៅកម្ពុជា" ("របាយការណ៍"), https://cchrcambodia.org/admin/media/report/report/english/2016_02_11_CCHR_Report_Access_to_Collective_Land_Titles_ENG.pdf ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១។
អង្គការទិន្នន័យអំពីការអភិវឌ្ឍ បានលើកឡើងអំពីការចុះបញ្ជីដីសហគមន៍ជាបីដំណាក់កាលផ្សេងៗគ្នា៖ ក្រសួងអភិវឌ្ឍន៍ជនបទចេញលិខិតទទួលស្គាល់សហគមន៍ជាសហគមន៍ជនជាតិដើមភាគតិច។ (គិតត្រឹមខែមិថុនា ឆ្នាំ២០១៨ មានសហគមន៍ចំនួន ១៤១ បានទទួល)។ ក្រសួងមហាផ្ទៃចុះបញ្ជីសហគមន៍ជានីតិបុគ្គល (មានសហគមន៍ចំនួន ១២៨ បានទទួល)។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះពិនិត្យទីតាំងដី និងចេញបណ្ណកម្មសិទ្ធិ (មានសហគមន៍ចំនួន ២៤ ត្រូវបានផ្តល់បណ្ណកម្មសិទ្ធិ)។ វិធី ៣ ខុសគ្នាដើម្បីទទួលបានដីធ្លីនេះ ត្រូវបានអនុញ្ញាតតាមអនុក្រឹត្យលេខ ៨៣ (ក្របខណ្ឌដែលសហគមន៍ជនជាតិដើមភាគតិចអាចទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាព)។
https://opendevelopmentcambodia.net/topics/communal-land/
បានចូលមើលនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២១។

៦. Indexmundi. "ប្រវត្តិប្រជាសាស្ត្រកម្ពុជា ២០១៤, http://www.indexmundi.com/cambodia/demographics_profile.html", បានចូលមើលនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០២១។

៧. មូល ផាត, សេង សុវឌ្ឍនា. កំណត់សម្គាល់បច្ចេកទេសប្រចាំប្រទេស ស្ដីពីបញ្ហាជនជាតិដើមភាគតិច៖ ព្រះរាជាណាចក្រកម្ពុជា. IFAD/AIPP, ខែវិច្ឆិកា ឆ្នាំ២០១៧. បានចូលមើលនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។ https://www.ifad.org/documents/38714170/40224860/cambodia_ctn.pdf/02148186-48e9-4c08-bc09-b3565da70afb

៨. ក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ (Minority Rights Group International), សៀវភៅបញ្ជីឈ្មោះជនជាតិភាគតិច និងជនជាតិដើមភាគតិចនៅលើពិភពលោក - ជនជាតិដើមភាគតិចនៅកម្ពុជា៖ ខែវិច្ឆិកា ឆ្នាំ២០១៧ អាចរកបាននៅ៖ https://www.refworld.org/docid/5b9b75bf7.html, បានចូលមើលនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២១។

៩. យោងតាមផាត និង សុវឌ្ឍនា៖ “ព្រះរាជាណាចក្រកម្ពុជា៖ កំណត់សម្គាល់បច្ចេកទេសប្រចាំប្រទេស ស្ដីពីបញ្ហាជនជាតិដើមភាគតិច” ទំព័រ ៩ ឆ្នាំ២០១៧ មានជនជាតិដើមភាគតិចនៅកម្ពុជាមានចំនួន ២៤ អំបូរ ។ https://www.ifad.org/documents/38714170/40224860/cambodia_ctn.pdf/02148186-48e9-4c08-bc09-b3565da70afb, បានចូលមើលនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

១០. កម្ពុជា,” Ethnologue, https://www.ethnologue.com/country/kh, បានចូលមើលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១

១១. វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា “គម្រោងសិទ្ធិជនជាតិដើមភាគតិច”, https://www.ngoforum.org.kh/indigenous-people-rights-project / បានចូលមើលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

១២. អង្គការទិន្នន័យអំពីការអភិវឌ្ឍ, ជនជាតិភាគតិច និងជនជាតិដើមភាគតិច ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ https://opendevelopmentcambodia.net/topics/ethnic-minorities-and-indigenous-people/, ធ្វើបច្ចុប្បន្នភាពចុងក្រោយថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ បានចូលមើលនៅ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

១៣. រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០១b ច្បាប់ភូមិបាលឆ្នាំ២០០១ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទំព័រ ១៤០៩ មាត្រា ២៣។

១៤. ពិភពជនជាតិដើមភាគតិចឆ្នាំ២០១៩ កែសម្រួលដោយ៖ David Nathaniel Berger https://www.iwgia.org/images/documents/indigenous-world/IndigenousWorld2019_UK.pdf

១៥. អង្គការឃ្លាំមើលសិទ្ធិមនុស្ស, របាយការណ៍ពិភពលោកឆ្នាំ២០២០, ជំពូកអំពីប្រទេសកម្ពុជា https://www.hrw.org/world-report/2020/country-chapters/cambodia, បានចូលមើលនៅថ្ងៃទី២៨ ខែមិនា ឆ្នាំ២០២១។

**១៦.** ក្រុមការងារអន្តរជាតិស្តីពីកិច្ចការជនជាតិដើមភាគតិច (IWGIA). ពិភពជនជាតិដើមភាគតិច៖ កម្ពុជា. IWGIA, ឆ្នាំ ២០១៩, ទំព័រ ២៥៤ https://www.iwgia.org/images/documents/indigenous-world/IndigenousWorld2019_UK.pdf, បានចូលមើលនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

**១៧.** ក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ សៀវភៅបញ្ជីឈ្មោះជនជាតិភាគតិច និងជនជាតិដើមភាគតិចនៅលើពិភពលោក - ជនជាតិដើមភាគតិចនៅកម្ពុជា៖ ខែវិច្ឆិកា ឆ្នាំ២០១៧, អាចរកបាននៅ៖ https://www.refworld.org/docid/5b9b75bf7.html, បានចូលមើលនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

**១៨.** ពិភពលោកជនជាតិដើមឆ្នាំ២០១៩ កែសម្រួលដោយ៖ David Nathaniel Berger https://www.iwgia.org/images/documents/indigenous-world/IndigenousWorld2019_UK.pdf

**១៩.** អង្គការទិន្នន័យអំពីការអភិវឌ្ឍ, ដីសមូហភាព, ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥ https://opendevelopmentcambodia.net/topics/communal-land/ , បានចូលមើលនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

**២០.** វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា. “គម្រោងសិទ្ធិជនជាតិដើមភាគតិច.” បានចូលមើលនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៦. https://www.ngoforum.org.kh/indigenous-people-rights-project /

**២១.** អង្គការទិន្នន័យអំពីការអភិវឌ្ឍ ជនជាតិភាគតិច និងជនជាតិដើមភាគតិច ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦, https://opendevelopmentcambodia.net/topics/ethnic-minorities-and-indigenous-people/ , ធ្វើបច្ចុប្បន្នភាពចុងក្រោយថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩, បានចូលមើលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

**២២.** ក្រុមការងារអន្តរជាតិស្តីពីកិច្ចការជនជាតិដើមភាគតិច (IWGIA). ពិភពជនជាតិដើមភាគតិច៖ កម្ពុជា. IWGIA, ២០១៦. បានចូលមើលនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៦.https://www.iwgia.org/images/publications//0740_THE_INDIGENOUS_ORLD_2016_final_eb.pdf

**២៣.** អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD)

**២៤.** អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)

**២៥.** កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)

**២៦.** កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR)

**២៧.** អនុសញ្ញាស្តីពីជីវចម្រុះ (CDB)

**២៨.** អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)

**២៩.** “តាមការសន្មត” នៅក្នុងឯកសារនេះ មានន័យថា ក្របខណ្ឌច្បាប់មានជាផ្លូវការ ប៉ុន្តែមិនមានប្រសិទ្ធភាពអនុវត្ត។

**៣០.** មាត្រា ២៥ ចែងអំពីកម្មសិទ្ធិដីសមូហភាព ខណៈដែលមាត្រា ២៦ ទទួលស្គាល់ពីតួនាទីរបស់អាជ្ញាធរ យន្តការបែបប្រពៃណី និងទំនៀមទម្លាប់ក្នុងការសម្រេចចិត្ត និងអនុវត្តសិទ្ធិកម្មសិទ្ធិ។ យោងតាមមាត្រា ២៨ ចែងថា គ្មានអាជ្ញាធរណាមួយនៅក្រៅសហគមន៍អាចទទួលបានសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចឡើយ។

**៣១.** សេចក្តីសម្រេចលេខ ៣៩ COM ១១ (២០១៥); ៣៧ COM ១២.II (២០១៣)។

**៣២.** IFAD, កំណត់សម្គាល់បច្ចេកទេសប្រចាំប្រទេស ស្តីពីបញ្ហាជនជាតិដើមភាគតិច ព្រះរាជាណាចក្រកម្ពុជា. https://www.ifad.org/documents/38714170/40224860/cambodia_ctn.pdf/02148186-48e9-4c08-bc09-b3565da70afb, ២០១២, បានចូលមើលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

**៣៣.** IFAD, កំណត់សម្គាល់បច្ចេកទេសប្រចាំប្រទេស ស្តីពីបញ្ហាជនជាតិដើមភាគតិច ព្រះរាជាណាចក្រកម្ពុជា. https://www.ifad.org/documents/38714170/40224860/cambodia_ctn.pdf/02148186-48e9-4c08-bc09-b3565da70afb, ២០១២, បានចូលមើលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

